ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤

រាជធានីភ្នំពេញ ថ្ងៃសុក្រ ១១ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០២១

មាតិកា

I. សេចក្តីផ្តើម.....១

១. បេសកកម្ម តួនាទី និងការកិច្ច ៣

២. គោលបំណងគោលនយោបាយរយៈពេលមធ្យម ៤

៣. លទ្ធផល ការប្រឈម និងវិធានការ ៦

៣.១. លទ្ធផល និងការប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០២០ .....៦

៣.២- លទ្ធផលនិងការប្រឈមនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣..... ១៤

II. គោលបំណងគោលនយោបាយ ២១

III. ការរៀបចំកម្មវិធី សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០២២-២០២៤.....២៥

IV. ការរៀបចំសូចនាករគោល និងគោលដៅ ២៨

V. តម្រូវការធនធានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤..... ៣៤

VI . សេចក្តីសន្និដ្ឋាន.....៣៩

I. សេចក្តីផ្តើម

ក្នុងគោលបំណងបង្កើនស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃការរួមចំណែកសម្រេចគោលដៅលុបបំបាត់ ភាពក្រីក្រនិងកសាងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដែលជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានកំណត់ជាក់ឲ្យអនុវត្តតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០១៦-២០៣០ ព្រមទាំងត្រូវបានគូសញ្ជាក់លម្អិតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ក្រសួងអភិវឌ្ឍន៍ជនបទបាននិងកំពុងរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទរយៈពេលដប់ឆ្នាំ២០២១-២០៣០ ដែលមានចក្ខុវិស័យ **ភូមិសាស្ត្រជនបទស៊ីវិលល្អនៅឆ្នាំ២០៣០** តាមរយៈការដាក់ឲ្យអនុវត្តនូវគោលនយោបាយពីរគឺ **ការលើកកម្ពស់សុខមាលភាពសង្គមជនបទ និងការបង្កើនសុខវឌ្ឍនភាពជនបទ**។

ដើម្បីអនុវត្តនូវគោលនយោបាយទាំងពីរខាងលើ ដែលជាមូលដ្ឋានគ្រឹះក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យនៃការកសាងសង្គមជនបទស៊ីវិលល្អ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំកម្មវិធីចំនួនប្រាំគឺ កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ, កម្មវិធីអភិវឌ្ឍន៍សុខភាពនិងកែលម្អលក្ខខណ្ឌរស់នៅជនបទ, កម្មវិធីអភិវឌ្ឍន៍សហគមន៍ជនបទ, កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទ, និងកម្មវិធីអភិវឌ្ឍន៍គោលនយោបាយនិងពង្រឹងអភិបាលកិច្ច។ កម្មវិធីទាំងប្រាំនេះគឺជាកម្មវិធីគន្លឹះរួមចំណែកបំពេញឲ្យគ្នាក្នុងការគាំទ្រគោលនយោបាយទាំងពីរឲ្យសម្រេចបានតាមគោលដៅ។ ការកំណត់គោលនយោបាយនិងការរៀបចំកម្មវិធីនេះ តម្រូវឲ្យមានការកែសម្រួលផង និងបង្កើតថ្មីផងនូវបណ្តាសកម្មភាព, ចង្អោមសកម្មភាព, និងអនុកម្មវិធីដែលទាមទារពេលវេលាផង និងការយកចិត្តទុកដាក់ខ្ពស់ផង ព្រោះមានលក្ខណៈខុសគ្នាខ្លះបើធៀបទៅនឹងការកំណត់គោលនយោបាយនិងការរៀបចំកម្មវិធីរបស់ក្រសួងពីមុនមកគឺ៖

- ពីឆ្នាំ២០១៨-២០២០ មានគោលនយោបាយចំនួនពីរគឺ (១) **ជំរុញកំណើនសេដ្ឋកិច្ចជនបទតាមរយៈការអភិវឌ្ឍជនបទចម្រុះដោយមានការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ និង(២)ធានាលើក កម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យមានគម្លាតខិតជិតទីប្រជុំជននៅឆ្នាំ២០២៥** ដែលអនុវត្តដោយកម្មវិធី ៣គឺ (១) ស្តារ ថែទាំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ, (២) បន្តលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទឲ្យកាន់តែប្រសើរឡើង, និង(៣) បន្តកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស។
- ពីឆ្នាំ២០២០-២០២១ មានគោលនយោបាយមួយគឺ **លើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ធទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌** ដែលអនុវត្តដោយកម្មវិធី ៤គឺ (១) អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទ, (២) កែលម្អលក្ខខណ្ឌរស់នៅសហគមន៍ជនបទ, (៣) ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ, និង (៤) ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ។

ទន្ទឹមនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកែលម្អទាំងទម្រង់ និងកិច្ចដំណើរការក្នុងការរៀបចំផែនការ

យុទ្ធសាស្ត្រថវិកាដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការរៀបចំ និងបង្កើនការផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងគោលនយោបាយផងព្រមទាំងបង្កើនសមត្ថភាព និងការទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយផង។ ក្នុងន័យនេះ ក្រសួងបានចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ លម្អិតដល់ប្រធានកម្មវិធី និងអង្គភាពប្រតិបត្តិ និងបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាជា ៣កម្រិតគឺ (១) **ផែនការយុទ្ធសាស្ត្រថវិកាក្រសួង**ដែលជាផែនការយុទ្ធសាស្ត្រថវិកាសម្រាប់អនុវត្តគោលនយោបាយរបស់ក្រសួង, (២) **ផែនការយុទ្ធសាស្ត្រថវិកាកម្មវិធី** ដែលជាផែនការយុទ្ធសាស្ត្រលម្អិតសម្រាប់អនុវត្តកម្មវិធីនីមួយៗ, និង (៣) **ផែនការយុទ្ធសាស្ត្រថវិកាអង្គភាពប្រតិបត្តិ**ដែលជាផែនការយុទ្ធសាស្ត្រលម្អិតសម្រាប់អនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋាន និងមន្ទីរជំនាញរាជធានីខេត្ត។ ផែនការយុទ្ធសាស្ត្រថវិកាក្រសួងគឺជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រកម្មវិធី និងផែនការយុទ្ធសាស្ត្រអង្គភាពប្រតិបត្តិ ព្រមទាំងសម្រាប់គាំទ្រគោលនយោបាយ និងការពារក្នុងការស្វែងរកថវិកា។ ផែនការយុទ្ធសាស្ត្រថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកាអង្គភាពប្រតិបត្តិ គឺជាឯកសារមូលដ្ឋានសម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រថវិកាក្រសួងផង និងជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងនិងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកានៅក្នុងផ្ទៃក្នុងរបស់ក្រសួងផង។

ការបង្កើនប្រសិទ្ធភាព និងសមត្ថភាពនៃការរៀបចំគោលនយោបាយមិនត្រឹមតែត្រូវចំណាយថវិកា, ពេលវេលា, ជំនាញ, និងធនធានក្នុងការដោះស្រាយបញ្ហានិងការប្រឈមប៉ុណ្ណោះទេ ប៉ុន្តែប្រសិនបើគោលនយោបាយដ៏ត្រឹមត្រូវច្បាស់លាស់នេះមិនត្រូវបានយកទៅអនុវត្តនោះមិនត្រឹមតែខាតបង់ថវិកា, ពេលវេលា, ជំនាញ, និងធនធានក្នុងការរៀបចំគោលនយោបាយប៉ុណ្ណោះទេ ថែមទាំងមិនអាចសម្រេចបាននូវបណ្តាគោលដៅនៃគោលនយោបាយ និងចក្ខុវិស័យក្នុងការកសាងសង្គមជនបទស៊ីវិល័យ ក៏ដូចជាគោលដៅលុបបំបាត់ភាពក្រីក្រ និងការកសាងប្រទេសឲ្យមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ទៀតផង។

ប្រាកដណាស់ថា ការបង្កើនគុណភាពគោលនយោបាយអភិវឌ្ឍន៍ជនបទដើម្បីឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ និងជាក់ស្តែងរបស់ប្រជាពលរដ្ឋជនបទផង និងបង្កើនស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពក្នុងការរួមចំណែកលុបបំបាត់ភាពក្រីក្រ និងកសាងប្រទេសឲ្យមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ផង ក្រសួងអភិវឌ្ឍន៍ជនបទពិតជាត្រូវការថវិកាច្រើនជាងមុនបើធៀបទៅនឹងគោលនយោបាយ និងកម្មវិធីបច្ចុប្បន្ន។ ទោះជាយ៉ាងណា សារៈសំខាន់និងភាពចាំបាច់នៃគោលនយោបាយ និងកម្មវិធីដែលបានកំណត់និងរៀបចំមកនេះ ពិតជាត្រូវបានធ្វើអាទិភាពកម្មទៅតាមសកម្មភាព, ចង្អោមសកម្មភាព, និងអនុកម្មវិធីដែលមានគោលបំណង, សូចនាករ, និងគោលដៅត្រឹមត្រូវច្បាស់លាស់អាចវាស់វែងបាន ព្រមទាំងមានអង្គភាព និងអ្នកទទួលខុសត្រូវប្រកបដោយគណនេយ្យភាពដែលពិតជាអាចធានាបាននូវការអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាព, ប្រសិទ្ធភាព, ផលិតភាព, គណនេយ្យភាព, និង តម្លាភាព តាមរយៈការអនុវត្តនូវផែនការយុទ្ធសាស្ត្រថវិកា ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាជាប្រព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកាទាំង ៣កម្រិតដូចបានគូសបញ្ជាក់ខាងលើ។

១. បេសកកម្ម តួនាទី និងភារកិច្ច

ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានបង្កើតឡើងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦។ ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងវិស័យអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដែលមានមុខងារនិងការកិច្ចសំខាន់ៗដូចខាងក្រោម៖

- កំណត់គោលនយោបាយនិងយុទ្ធសាស្ត្រនៃការអភិវឌ្ឍជនបទ ស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- លើកទិសដៅផែនការយៈពេលខ្លី មធ្យម និងវែង លើការងារអភិវឌ្ឍន៍ជនបទដើម្បីកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទទូទៅដោយរួមបញ្ចូលទាំងជនជាតិភាគតិចក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យកាន់តែល្អប្រសើរឡើង កាត់បន្ថយជាបណ្តើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទនិងអ្នកទីក្រុង។
- ចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយកម្រិតសកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា។
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មាន ស្ថិតិ អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទាំងតំបន់ភ្នំ តំបន់ខ្ពង់រាប និងតំបន់វាលរាប។
- អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រី បុគ្គលិករាជការរបស់ក្រសួង។
- រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង។
- អប់រំ ផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ។
- ធ្វើទំនាក់ទំនង សម្របសម្រួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ ព្រមទាំងប្រជារាស្ត្រមូលដ្ឋានដើម្បីធ្វើការអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាព។
- គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

២. គោលបំណងគោលនយោបាយរយៈពេលមធ្យម

ស្របតាមបេសកកម្ម តួនាទី និងការកិច្ចដែលបានកំណត់ខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបាន និងកំពុងរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទរយៈពេលវែង២០២១-២០៣០ ដែលមានចក្ខុវិស័យ "**ឆ្ពោះសម្រេចជនបទស៊ីវិល័យនៅឆ្នាំ២០៣០**" និងរួមចំណែកក្នុងការអនុវត្តគោលដៅលុបបំបាត់ភាពក្រីក្រ និងការកសាងប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលនយោបាយពីរគឺ "**ការលើកកម្ពស់សុខមាលភាពសង្គមជនបទ**និង**ការបង្កើនសុខវឌ្ឍនភាពជនបទ**" ដែលត្រូវដាក់ឲ្យអនុវត្តតាមអភិក្រម ៣ដំណាក់កាលគឺ៖ **(១) ការកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យ២០២១-២០២៣, (២) ការសាងសង់សង្គមជនបទស៊ីវិល័យ២០២៤-២០២៨, និង(៣) ការបំពេញនិងរក្សានិរន្តរភាពសង្គមជនបទស៊ីវិល័យ២០២៩-២០៣០** ដូចមានបង្ហាញក្នុងដ្យាក្រាមខាងក្រោម:



ដើម្បីអនុវត្តគោលនយោបាយតាមអភិក្រមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលបំណងគោលនយោបាយរយៈពេលមធ្យម ឆ្នាំ២០២១-២០២៤ គឺ **"ការកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យ"** ពោលគឺ**ការកសាងមូលដ្ឋានគ្រឹះនៃសុខុមាលភាពនិងសុខវឌ្ឍនភាពសង្គមជនបទ** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២២-២០២៤ តាមរយៈការកសាងមូលដ្ឋានគ្រឹះនៃជនបទមានជីវភាពសមរម្យ, មូលដ្ឋានគ្រឹះនៃជនបទមានសុខភាពមាំមួន, មូលដ្ឋានគ្រឹះនៃជនបទមានសហគមន៍ថ្លៃថ្នូរ, មូលដ្ឋានគ្រឹះនៃជនបទមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍សមាហរណ, និងមូលដ្ឋានគ្រឹះនៃជនបទមានគោលនយោបាយនិងអភិបាលកិច្ចល្អ ដែលជាគោលដៅដំណាក់កាលទី១ នៃចក្ខុវិស័យកសាងសង្គមជនបទស៊ីវិល័យ ឆ្នាំ២០៣០។

ដូច្នេះ បើធៀបនឹងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ក្រសួងអភិវឌ្ឍន៍ជនបទបានកែសម្រួលគោលបំណងគោលនយោបាយពី **"លើកកម្ពស់គុណភាពនិងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ទទាំងផ្នែក សេដ្ឋកិច្ច សង្គម និងវប្បធម៌"** មកជា **"ការកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យ"** ឬ **"ការកសាងមូលដ្ឋានគ្រឹះនៃសុខុមាលភាពនិងសុខវឌ្ឍនភាព សង្គមជនបទ"** វិញដើម្បីឲ្យស្របនឹងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ២០២១-២០៣០ ផង និង ដើម្បីផ្សារភ្ជាប់ទៅនឹងការរួមចំណែកក្នុងការសម្រេចគោលដៅលុបបំបាត់ភាពក្រីក្រ និងកសាងប្រទេសឲ្យមាន ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក៏ដូចជាយុទ្ធ សាស្ត្រចតុកោណដំណាក់កាលទី៤ និងចក្ខុវិស័យកម្ពុជារបស់រាជរដ្ឋាភិបាលដែលត្រូវបានដាក់ឲ្យអនុវត្ត តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។

គោលបំណងគោលនយោបាយរយៈពេលមធ្យម ២០២២-២០២៤

៣. លទ្ធផល ការប្រឈម និងវិធានការ

៣.១. លទ្ធផល និងការប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០២០

យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៣ សរណន ចុះថ្ងៃអង្គារ ៤រោច ខែជេស្ថ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ បានកំណត់កញ្ចប់ថវិកា៣ឆ្នាំរំកិល សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទសរុបចំនួន ៩៣៦ ១២៧ លានរៀល ក្នុងនោះ៖ ឆ្នាំ២០២១ ចំនួន ៣០៥ ៦៦៨លានរៀល, ឆ្នាំ២០២២ ចំនួន ៣១០ ១៣០លានរៀល, និងឆ្នាំ២០២៣ ចំនួន ៣២០ ៣២៩លានរៀល បើធៀបទៅនឹងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ដែលមានត្រឹមតែចំនួន ៥៦៩ ៤២៤លានរៀល កញ្ចប់ថវិកា ៣ឆ្នាំរំកិលនេះ មានកំណើនរហូតដល់ ៦៤% សម្រាប់រយៈពេល ៣ឆ្នាំក្នុងនោះ ឆ្នាំ២០២១ មានកំណើន ៦១% ពីចំនួន ១៨៩ ៧២២លានរៀល និងឆ្នាំ២០២២ មានកំណើន ៥៨% ពីចំនួន ១៩៦ ៥១០ លានរៀល។ បម្រែបម្រួលនៃកញ្ចប់ថវិកា ៣ឆ្នាំរំកិលនេះ គឺជាមូលដ្ឋានសម្រាប់ការរៀបចំ និងកែ សម្រួលផែនការសកម្មភាព, កម្មវិធី, និងគោលបំណងគោលនយោបាយក្នុងការអនុវត្តគោលនយោបាយ **លើកកម្ពស់គុណភាពនិងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទប្រកបដោយបរិយាប័ន្ទទាំងផ្នែក សេដ្ឋកិច្ច សង្គម និងវប្បធម៌** របស់ក្រសួងក្នុងគោលដៅជានាការរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។

គោលបំណងគោលនយោបាយខាងលើ ត្រូវបានអនុវត្តតាមរយៈកម្មវិធី ៤គឺ (១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍, (២) កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ (៣) ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ, និង (៤) ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅដោយបានប្រើប្រាស់ថវិការដ្ឋសរុបចំនួន ៤៥៥ ៣០៤,៥លានរៀល ស្មើ ១១៧,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៨៦ ៧២៣លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ៨ ៨០៤,៧លានរៀល ស្មើ ៦៨,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១២ ៧៨៥,៩លានរៀល, ជំពូក ៦១ ចំនួន ១៣២ ១៧៤,៣ លានរៀល ស្មើ ៨៩,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៤៦ ៩៩៦,៨លានរៀល, ជំពូក ៦៤ ចំនួន ៣៤ ៩៤៥,៧លានរៀល ស្មើ ៩៦,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៦ ២៨១,៣ លានរៀល, ជំពូក ៦៥ ចំនួន ៤១០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ, ជំពូក ៦៣ ចំនួន ១៩៣លានរៀល ស្មើ ៩៤,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២០៤លានរៀល, និងជំពូក ២១ ចំនួន ២៧៨ ៧៧៦,៨លានរៀល ស្មើ ១៤៦,៧% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៩០ ០០០ លានរៀល។ ការអនុវត្តចំណាយខាងលើត្រូវបានឆ្លុះបញ្ចាំងទៅតាមកម្មវិធី និងជំពូកដូចខាងក្រោម៖

កម្មវិធីទី ១៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ អនុវត្ត បាន ៣៨៨ ៣៥៩,១លានរៀល ស្មើ ១២៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣០៧ ៧៤៨,៥ លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៣៦០,៩លានរៀល ស្មើ ៣៤,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ០៥៣,៨លានរៀល, ជំពូក ៦១ ចំនួន ១០៨ ៩២១,៤លានរៀល ស្មើ ៩៣,៦% ធៀបច្បាប់

ហិរញ្ញវត្ថុដែលមានចំនួន ១១៦ ៣៩៤,៧លានរៀល, ជំពូក ៦៥ ចំនួន ៣០០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ, និងជំពូក ២១ ចំនួន ២៧៨ ៧៧៦,៨លានរៀល ស្មើ ១៤៦,៧% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៩០ ០០០លានរៀល ដោយសារការបន្ថែមឥណទានរបស់រាជរដ្ឋាភិបាលសម្រាប់ជួសជុលផ្លូវដែលរងការខូចខាតដោយសារទឹកជំនន់។ **ជាលទ្ធផល កម្មវិធីទី ១ សម្រេចបាន ៩៥,២% ធៀបនឹងគោលដៅប្រចាំឆ្នាំនិងត្រូវបានលម្អិតតាមអនុកម្មវិធីដូចខាងក្រោម៖**

- **អនុកម្មវិធីទី ១៖ ការជួសជុលនិងរក្សាគុណភាពផ្លូវជនបទ** អនុវត្តបាន ៩៤ ៦៣៨,១ លានរៀល ស្មើ ៩៤,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១០០ ៤៩៨,១លានរៀល ក្នុងនោះ ជំពូក ៦១ ចំនួន ៩៤ ៣៣៨,១លានរៀល ស្មើ ៩៤,៥% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៩៩ ៧៩៤,៩លានរៀល, និងជំពូក ៦៥ ចំនួន ៣០០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ អនុកម្មវិធីទី ១ នេះសម្រេចលទ្ធផលបាន ១០០% ក្នុងនោះ៖ (១) ថែទាំផ្លូវក្រាលក្រួសក្រហមជាលក្ខណៈខួបបានប្រវែង ៤៣២,១៨គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ២៥ រាជធានីខេត្ត, (២) ថែទាំផ្លូវក្រាលក្រួសក្រហមជាលក្ខណៈប្រចាំបានប្រវែង ២ ៨៣៥.៧៤គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅទូទាំង ២៥ រាជធានីខេត្ត, និង (៣) ជួសជុលផ្លូវរងការខូចខាតមិនអាចចរាចរបានដោយអន្លើៗបានប្រវែង ២៩៤គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅទូទាំង ២៥ រាជធានីខេត្ត។

- **អនុកម្មវិធីទី ២៖ ការពង្រីកវិសាលភាពនៃការស្ថាបនាលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ** អនុវត្តបាន ២៧៨ ៧៧៦,៨លានរៀល ស្មើ ១៤៦,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៩០ ០០០,០លានរៀល ដោយប្រើប្រាស់ថវិកាជំពូក ២១។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ១០០% ក្នុងនោះ៖ (១) ស្ថាបនាផ្លូវក្រាលក្រួសក្រហមបានប្រវែង ២៦៨.១៤គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ១៨ រាជធានីខេត្ត, (២) ស្ថាបនាផ្លូវក្រាលកៅស៊ូ ពីរជាន់បានប្រវែង ១០៨.៩៨គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ១២រាជធានីខេត្ត, និង(៣) ស្ថាបនាផ្លូវក្រាលបេតុងបានប្រវែង ៩,៩គ.ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ៣ រាជធានីខេត្ត។

- **អនុកម្មវិធីទី ៣៖ ការរៀបចំបញ្ជីសារពើភ័ណ្ឌនិងមូលដ្ឋានទិន្នន័យផ្លូវជនបទ** អនុវត្តបាន ១៤២លានរៀល ស្មើ ២០,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦៨៣លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៤០,៤លានរៀល ស្មើ ១៣,៨% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៩២លានរៀល, និងជំពូក ៦១ ចំនួន ១០១,៦លានរៀល ស្មើ ២៦,០% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៩១ លានរៀល។ អនុកម្មវិធីទី ៣ នេះសម្រេចលទ្ធផលបាន ៨៩,០% ក្នុងនោះ៖ (១) ផលិតផែនទីផ្លូវជនបទបានចំនួន ១៨៣ផ្ទាំង ស្មើ ៨០,០% ធៀបគោលដៅប្រចាំឆ្នាំដែលមានចំនួន ២០៣ ផ្ទាំង ដោយអនុវត្តនៅទូទាំង ២៥រាជធានីខេត្ត, និង(២) ផលិតសៀវភៅបញ្ជីសារពើភ័ណ្ឌផ្លូវជនបទបានប្រវែង ៤៦ ៨៤២.៦៧គ.ម. ស្មើ ៩៧,៧%ធៀបគោលដៅប្រចាំឆ្នាំដែលមានប្រវែង ៤៧ ៨៤២.៦៧ ដោយអនុវត្តនៅទូទាំង ២៥ រាជធានី ខេត្ត។

- **អនុកម្មវិធីទី ៤. ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដោយមន្ទីរជំនាញរាជធានីខេត្ត**

អនុវត្តបាន ១៤ ៨០២,៣លានរៀល ស្មើ ៨៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៦ ៥៦៧,៤ លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៣២០,៥លានរៀល ស្មើ ៨៩,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៥៨,៦លានរៀល, និងជំពូក ៦១ ចំនួន ១៤ ៤៨១,៧លានរៀល ស្មើ ៩៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៦ ២០៨,៨លានរៀល។ **អនុកម្មវិធីទី ៤ សម្រេចលទ្ធផលបាន ៩១,៧% ធៀបនឹងគោលដៅប្រចាំឆ្នាំ**។

កម្មវិធីទី ២ៈ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ អនុវត្តបានចំនួន ១១ ៨២១,៣លានរៀល ស្មើ ៨៨,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៣ ៣៣៤,៣ លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ២១៤ លានរៀល ស្មើ ៨១,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៦២,២លានរៀល, ជំពូក ៦១ ចំនួន ១១ ៤៩៧,៣លានរៀល ស្មើ ៨៨,៧% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១២ ៩៦២,១លានរៀល, និងជំពូក ៦៥ ចំនួន ១១០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ ដោយសារសិក្ខាសាលា និងការបណ្តុះបណ្តាលពុំបានអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលដើម្បីការពារជំងឺកូវីដ ១៩។ **ជាលទ្ធផល កម្មវិធីទី ២ សម្រេចបាន ៩៣,៩% ធៀបនឹងគោលដៅប្រចាំឆ្នាំនិងត្រូវបានលម្អិតតាមអនុកម្មវិធីដូចខាងក្រោម៖**

- **អនុកម្មវិធីទី ១ៈ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ** អនុវត្តបាន ៥ ៦០៥,៧ លានរៀល ស្មើ ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ដោយប្រើប្រាស់ថវិកាជំពូក ៦១។ អនុកម្មវិធីទី ១ នេះ សម្រេចលទ្ធផលបាន ១០០% ក្នុងនោះ៖ (១) សាងសង់អណ្តូងស្នប់អាហ្ស្រ៊ីដេវបានចំនួន ២៧៥អណ្តូង ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ២១រាជធានីខេត្ត, (២) សាងសង់/ស្តារស្រះសហគមន៍បានចំនួន ១២ស្រះ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ១០រាជធានីខេត្ត (ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តកណ្តាល, ខេត្តកោះកុង, ខេត្តឧត្តរមានជ័យ, រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, ខេត្តព្រះវិហារ, ខេត្តស្វាយរៀង, និងខេត្តតាកែវ), (៣) សាងសង់អាងត្រង់ទឹកភ្លៀងបានចំនួន ៧១អាង ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ៤ខេត្ត (ខេត្តមណ្ឌលគិរី, ខេត្តប៉ៃលិន, ខេត្តរតនគិរី, និងខេត្តក្រចេះ), (៤) សាងសង់ប្រព័ន្ធចែកចាយទឹកសហគមន៍បានចំនួន ៦កន្លែង ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ៦ ខេត្ត (ខេត្តបន្ទាយមានជ័យ, ខេត្តកែប, ខេត្តកោះកុង, ខេត្តព្រះវិហារ, ខេត្តស្ទឹងត្រែង, និងខេត្តស្វាយរៀង), (៥) សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ធុង ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ នៅខេត្តឧត្តរមានជ័យ, និង(៦) ស្តារប្រព័ន្ធស្រោចស្រពបានចំនួន ១ខ្សែ ប្រវែង ២ ១០០ ម. ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ នៅខេត្តខេត្តព្រៃវែង។
- **អនុកម្មវិធីទី ២ៈ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ** អនុវត្តបាន ៥៥៩លានរៀល ស្មើ ៤៧,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ១៨៥,៣លានរៀល ក្នុងនោះ ជំពូក ៦១ ចំនួន ៤៩១លានរៀល ស្មើ ៤៤,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ០៩៤,៧ លានរៀល, និងជំពូក ៦៥ ចំនួន ៦៨លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ១០០% ក្នុងនោះ៖ (១) សិក្ខាសាលាស្តីពីបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹកចំនួន ៣លើក/១៤៨នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានី

ភ្នំពេញ ២លើក និងនៅខេត្តស្វាយរៀង ១ លើក, (២) សិក្ខាសាលាស្តីពីការអប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់ទឹកស្អាតបានចំនួន ៣លើក/១៩១នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញ, (៣) កិច្ចប្រជុំពិគ្រោះយោបល់និងសិក្ខាសាលារៀបចំផែនការសុវត្ថិភាពទឹកបានចំនួន ៩លើក ស្មើ ១០០,0% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញ, និង(៤) ចុះតាមដាន និងត្រួតពិនិត្យការងារទឹកស្អាតជនបទបាន ១០០% នៅទូទាំងរាជធានីខេត្ត។

- **អនុកម្មវិធីទី ៣: ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តអនាម័យជនបទ** អនុវត្តបាន ២ ២៧៣,៩ លានរៀល ស្មើ ៩៨,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២ ៣០១,៤លាន រៀល ដោយប្រើថវិកាជំពូក ៦១។ អនុកម្មវិធីទី ៣ នេះសម្រេចលទ្ធផលបាន ៩៩,0% ក្នុងនោះ: (១) សាងសង់បង្គន់អនាម័យសម្រាប់ប្រជាជនជនបទបានចំនួន ៣ ៤៩០ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅ ១៣ខេត្ត (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តក្រចេះ, ខេត្តសៀមរាប, ខេត្តព្រះវិហារ, ខេត្តប៉ៃលិន, ខេត្តឧត្តរមានជ័យ, ខេត្តកំពង់ធ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តស្វាយរៀង, ខេត្តព្រះសីហនុ, ខេត្តកែប, និងខេត្តកោះកុង), និង(២) ស្រង់ទិន្នន័យបញ្ជីសារពើពន្ធបង្គន់អនាម័យនៅភូមិគោលដៅចំនួន ១២០ភូមិ ស្មើ ៩៧,0% ធៀបគោលដៅប្រចាំឆ្នាំ។

- **អនុកម្មវិធីទី ៤: ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ** អនុវត្តបាន ៧៨៤,៩លានរៀល ស្មើ ៥១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៥៣០,៣លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៥៥លានរៀល ស្មើ ៧៤,២% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៧៤,១ លានរៀល, ជំពូក ៦១ ចំនួន ៦៨៧,៩លានរៀល ស្មើ ៤៨,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៤១៤,២លានរៀល, និងជំពូក ៦៥ ចំនួន ៤២លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ អនុកម្មវិធីទី ៤ នេះសម្រេចលទ្ធផលបាន ៨១,0% ក្នុងនោះ: (១) ការពង្រឹងសមត្ថភាពស្ថាប័នក្នុងការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យជនបទ អនុវត្តបានចំនួន ៦វគ្គ ស្មើ ៥០,0% ធៀបគោលដៅប្រចាំឆ្នាំចំនួន ១២វគ្គ ដោយអនុវត្តនៅ ១៣ ខេត្ត (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តក្រចេះ, ខេត្តសៀមរាប, ខេត្តព្រះវិហារ, ខេត្តប៉ៃលិន, ខេត្តឧត្តរមានជ័យ, ខេត្តកែប, ខេត្តកំពង់ធ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តស្វាយរៀង, ខេត្តព្រះសីហនុ, និងខេត្តកោះកុង), (២) ចុះសិក្សាការប្រើប្រាស់បង្គន់អនាម័យដែលមានការកែលម្អរប្រកបដោយនិរន្តភាពក្នុងខេត្តគោលដៅបានចំនួន ២៣ឃុំ/១៣ខេត្ត ស្មើ ៨៨,0% ធៀបគោលដៅប្រចាំឆ្នាំ ២៦ឃុំ/១៣ខេត្ត (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តក្រចេះ, ខេត្តសៀមរាប, ខេត្តព្រះវិហារ, ខេត្តប៉ៃលិន, ខេត្តកែប, ខេត្តកំពង់ធ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តស្វាយរៀង, ខេត្តព្រះសីហនុ, ខេត្តឧត្តរមានជ័យ, និងខេត្តកោះកុង), (៣) សិក្ខាសាលានិងបណ្តុះបណ្តាលស្តីពីបង្កើនការប្រើប្រាស់បង្គន់អនាម័យដែលមានការកែលម្អរប្រកបដោយនិរន្តភាពបានចំនួន ៨៦វគ្គ/លើក ស្មើ ៩៩,0% ធៀបគោលដៅប្រចាំឆ្នាំចំនួន ៨៧វគ្គ/លើក ដោយអនុវត្តនៅ ១៣ខេត្ត (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តក្រចេះ, ខេត្តសៀមរាប, ខេត្តព្រះវិហារ, ខេត្តប៉ៃលិន, ខេត្តកែប, ខេត្តកំពង់ធ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តស្វាយរៀង, ខេត្តព្រះសីហនុ, ខេត្តឧត្តរមានជ័យ, និងខេត្តកោះកុង), (៤) បង្កើននិងពង្រឹងសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋានដំណើរការនិងសេវាដ្ឋបាលក្នុងនាយកដ្ឋានឱ្យបានប្រសើរឡើង អនុវត្តបាន ១០០% ធៀបគោលដៅប្រចាំឆ្នាំ, និង(៥) ការងារអប់រំជំងឺឆ្លងនិងសុខភាពផ្លូវភេទ អនុវត្តបានចំនួន ៣លើក ស្មើ

១០០% ធៀបគោលដៅប្រចាំឆ្នាំ។

- **អនុកម្មវិធីទី ៥៖ ការផ្តល់សេវាសុខភាព និងលក្ខខណ្ឌនៃការរស់នៅសម្រាប់សាធារណៈជន ដោយមន្ទីរជំនាញរាជធានី ខេត្ត** អនុវត្តបាន ២ ៥៩៧,៨លានរៀល ស្មើ ៩៥,៨%ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២ ៧១១,៦លានរៀល ក្នុងនោះជំពូក ៦០ ចំនួន ១៥៩លានរៀល ស្មើ ៩៦,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៦៥,៥លានរៀល និងជំពូក ៦១ ចំនួន ២ ៤៣៨,៨លានរៀល ស្មើ ៩៥,៨% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២ ៥៤៦,១លានរៀល។ **អនុកម្មវិធីទី ៥ សម្រេចលទ្ធផលបាន ៨៩,៤% ធៀបគោលដៅប្រចាំឆ្នាំ**។

កម្មវិធីទី ៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ អនុវត្តបាន ៣ ២៧៥,៩ លានរៀល ស្មើ ៥៧,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៥ ៧១៣,៧លានរៀល ក្នុងនោះជំពូក ៦០ ចំនួន ៤២១លានរៀល ស្មើ ៤៧,៧% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៨៨២លានរៀល, និងជំពូក ៦១ ចំនួន ២ ៨៥៥លានរៀល ស្មើ ៥៩,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៤ ៨៣១,៧ លានរៀល ដោយសារសិក្ខាសាលា ការបណ្តុះបណ្តាល និងការតាំងពិពណ៌មួយចំនួនពុំបានអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលដើម្បីការពារជំងឺកូវីដ ១៩។ **ជាលទ្ធផល កម្មវិធីទី ៣ សម្រេចបាន ៧១,០% ធៀបនឹងគោលដៅប្រចាំឆ្នាំនិងត្រូវបានលម្អិតតាមអនុកម្មវិធីដូចខាងក្រោម៖**

- **អនុកម្មវិធីទី ១៖ ការជំរុញ បង្កើតការងារ និងមុខរបរនៅជនបទ** អនុវត្តបាន ៥៥,៦ លានរៀល ស្មើ ១៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៥៦,៨ លានរៀល ដោយប្រើថវិកាជំពូក ៦១។ អនុកម្មវិធីទី ១ នេះសម្រេចលទ្ធផលបាន ៩៤,៤% ក្នុងនោះ៖ (១) សិក្ខាសាលាផ្សព្វផ្សាយគំនិតផ្តួចផ្តើមអាជីវកម្ម ៥លើក មានសិក្ខាកាម ១៥០ នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៤ (ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ចាម, និងខេត្តតាកែវ), (២) បណ្តុះបណ្តាលគំនិតកែច្នៃផលិតផលបាន ១វគ្គ មានសិក្ខាកាមចំនួន ២០នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្តកំពង់ឆ្នាំង, និង (៣) សិក្ខាសាលាផ្សព្វផ្សាយពីបទពិសោធន៍ និងការប្រឈមក្នុងការបង្កើតនិងគាំទ្រសហគមន៍សន្សំប្រាក់បាន ៦វគ្គ ស្មើ ៦៧,០% ធៀបគោលដៅប្រចាំឆ្នាំចំនួន ៩វគ្គ ដោយអនុវត្តនៅខេត្ត ៣ (ខេត្តកំពង់ឆ្នាំង, ខេត្តបន្ទាយមានជ័យ, និងខេត្តកំពត), (៣) បណ្តុះបណ្តាលភាពជាសហគ្រិនបានចំនួន ២៣វគ្គ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៦ (ខេត្តបាត់ដំបង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ធំ, ខេត្តសៀមរាប, និងខេត្តតាកែវ)។

- **អនុកម្មវិធីទី ២៖ ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ** អនុវត្តបាន ១០៨,៩ លានរៀល ស្មើ ៣៩,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៧៦,៤លានរៀល ដោយប្រើថវិកាជំពូក ៦១។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ៦២,៩% ក្នុងនោះ៖ (១) សិក្ខាសាលាផ្សព្វផ្សាយផលិតផលសម្រេចសហគមន៍បានចំនួន ០១លើក មានសិក្ខាកាមចំនួន ៤៥នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្តកំពង់ឆ្នាំង, (២) សិក្ខាសាលាស្វែងយល់ពីទីផ្សារផលិតផលជនបទបានចំនួន ៤លើក ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៤(ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ចាម, ខេត្តពោធិ៍សាត់, និងខេត្តបាត់ដំបង), (៣) ចុះតាមដានពិនិត្យការអនុវត្តការងារគម្រោង

ឥណទានចំនួន ១២លើក ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៧ (ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, ខេត្តបាត់ដំបង, ខេត្តតាកែវ, ខេត្តកំពត, ខេត្តសៀមរាប, និងខេត្តកំពង់ឆ្នាំង), និង (៤) រៀបចំពិព័រណ៍ផលិតផលសហគមន៍ជនបទបាន ៥០% ធៀបគោលដៅប្រចាំឆ្នាំ ដោយគ្រោងរៀបចំនៅខេត្តកំពង់ឆ្នាំង។

- **អនុកម្មវិធីទី ៣: ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព** អនុវត្តបាន ១ ០៣២ លានរៀល ស្មើ ៥៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៨៧៧,១លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៧៥ លានរៀល ស្មើ ២៣,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣១៨,១លានរៀល, និងជំពូក ៦១ ចំនួន ៩៥៧លានរៀល ស្មើ ៦១,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៥៥៩លានរៀល។ អនុកម្មវិធីទី ៣ នេះសម្រេចលទ្ធផលបាន ៧១,0% ក្នុងនោះ: (១) បណ្តុះបណ្តាលស្តីពីការអនុវត្តគោលនយោបាយអភិវឌ្ឍធនធានមនុស្សបានចំនួន ១0វគ្គ ស្មើ ៨៣,0% ធៀបគោលដៅប្រចាំឆ្នាំ ដែលមានចំនួន ១២វគ្គ ដោយអនុវត្តនៅរាជធានីខេត្ត ៣ (ភ្នំពេញ, កំពង់ស្ពឺ, និងកំពង់ធំ), (២) ចុះតាមដានវាយតម្លៃប្រសិទ្ធភាពការបណ្តុះបណ្តាលបានចំនួន ១៥ដង ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ, និង (៣) បណ្តុះបណ្តាលជំនាញមូលដ្ឋានបានចំនួន ៨៥វគ្គ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ១១ (ស្វាយរៀង, ព្រៃវែង, កំពង់ចាម, បាត់ដំបង, ពោធិ៍សាត់, កំពត, កំពង់ធំ, បន្ទាយមានជ័យ, សៀមរាប, កណ្តាល, និងកំពង់ឆ្នាំង)។

- **អនុកម្មវិធីទី ៤: ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ** អនុវត្តបាន ១ ១៣៤,៦ លានរៀល ស្មើ ៨៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៩៣៧,៦លានរៀល ក្នុងនោះជំពូក ៦0 ចំនួន ២១៧លានរៀល ស្មើ ៧៣,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៩៥,៦លានរៀល, និងជំពូក ៦១ ចំនួន ៩១៧,៦លានរៀល ស្មើ ៥៥,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៦៤២ លានរៀល។ អនុកម្មវិធីទី ៤ នេះសម្រេចលទ្ធផលបាន ៦៣,0% ក្នុងនោះ: (១) សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាពរបស់គណកម្មាធិការអភិវឌ្ឍន៍ភូមិបាន ៥៧វគ្គ ស្មើ ៦៨,0% ធៀបគោលដៅប្រចាំឆ្នាំដែលមានចំនួន ៨៤វគ្គ ដោយអនុវត្តនៅ ២៥រាជធានីខេត្ត, (២) ការអភិវឌ្ឍចម្រុះដោយបានចុះចែកកូនឈើនិងដីកស្រះជូនប្រជាពលរដ្ឋបាន ៥0,0% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៤ (ត្បូងឃ្មុំ, កំពង់ឆ្នាំង, ព្រៃវែង, និងស្វាយរៀង), (៣) បណ្តុះបណ្តាលដល់សហគមន៍ស្តីពីសួនដំណាំគ្រួសារនិងរបៀបធ្វើដីកំប៉ុស្ត៍, ការត្រៀមបង្ការនិងកាត់បន្ថយគ្រោះภัยក្នុងសហគមន៍, ការដាំដំណាំ ចិញ្ចឹមសត្ត ធ្វើសាប៊ូ ភាពជាអ្នកដឹកនាំ ចលនាភូមិថ្មី, ជំនាញវិជ្ជាជីវៈដូចជា កុំព្យូទ័ររដ្ឋបាល អ៊ីតសក់ផាត់មុខ ភាសាអង់គ្លេស ចិញ្ចឹមសត្ត និងដាំដំណាំ អនុវត្តបាន ៤១វគ្គ ស្មើ ៥៨,0% ធៀបគោលដៅប្រចាំឆ្នាំចំនួន ៧១វគ្គ ដោយអនុវត្តនៅខេត្ត ១0 (ក្រចេះ, ត្បូងឃ្មុំ, ពោធិ៍សាត់, បន្ទាយមានជ័យ, រតនគីរី, កំពង់ស្ពឺ, ព្រះសីហនុ, កែប, សៀមរាប, និងខេត្តតាកែវ)។

- **អនុកម្មវិធីទី ៥: ការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច** អនុវត្តបាន ២២៥,៩លានរៀល ស្មើ ៦0,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៧៤លានរៀល ក្នុងនោះជំពូក ៦0 ចំនួន ៣៣ លានរៀល ស្មើ ៨៥,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៨,៤ លានរៀល, និងជំពូក ៦១ ចំនួន ១៩២,៩លានរៀល ស្មើ ៥៧,៥% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៣៥,6លានរៀល។ អនុកម្មវិធីទី

៥ នេះសម្រេចលទ្ធផលបានចំនួន ១១ សហគមន៍ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយបានផ្សព្វផ្សាយការយល់ដឹងទៅដល់អាជ្ញាធរថ្នាក់ខេត្ត, មន្ទីរជំនាញ៣ក់ពន្ធ, សហគមន៍ជនជាតិដើមភាគតិចដោយអនុវត្តនៅខេត្តមណ្ឌលគិរី, និង (២) សិក្ខាសាលាផែនការយុទ្ធសាស្ត្រជាតិអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិចបាន ២វគ្គ ស្មើ ១០០,0% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញ។

- **អនុកម្មវិធីទី ៦៖ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទ ដោយមន្ទីរជំនាញរាជធានី ខេត្ត** អនុវត្តបាន ៧១៨,៩ លានរៀល ស្មើ ៨០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៨៩១,៨ លានរៀល។

កម្មវិធីទី ៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ អនុវត្តបាន ៥១ ៨៤៨,១លានរៀល ស្មើ ៨៥,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៥៩ ៩២៦,៥លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៧ ៨០៨,៨លានរៀល ស្មើ ៧៣,៨% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១០ ៥៨៧,៩លានរៀល, ជំពូក ៦១ ចំនួន ៨ ៩០០,៧លានរៀល ស្មើ ៦៩,៥% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១២ ៨០៨,៣លានរៀល, ជំពូក ៦៤ ចំនួន ៣៤ ៩៤៥,៧លានរៀល ស្មើ ៩៦,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៦ ២៨១,៣លានរៀល, និងជំពូក ៦៣ ចំនួន ១៩៣លានរៀល ស្មើ ៩៤,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២០៤លានរៀល ដោយសារសិក្ខាសាលានិងការបណ្តុះបណ្តាលលើវគ្គលទ្ធកម្មសាធារណៈនិងសវនកម្ម ។ល។ ពុំបានអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលដើម្បីការពារជំងឺកូវីដ ១៩។ **ជាលទ្ធផល កម្មវិធីទី ៤ សម្រេចបាន ៨៦,៦% ធៀបនឹងគោលដៅប្រចាំឆ្នាំ និងត្រូវបានលម្អិតទៅតាមកម្មវិធីដូចខាងក្រោម៖**

- **អនុកម្មវិធីទី ១៖ ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍជនបទ** អនុវត្តបាន ៤២០,៩លានរៀល ស្មើ ៥២,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៧៩៦,៣លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ៨៤លានរៀល ស្មើ ៧៦,៥% ធៀបច្បាប់ហិរញ្ញវត្ថុចំនួន ១០៩,៨លានរៀល, និងចំនួន ៦១ ចំនួន ៣៣៦,៩លានរៀល ស្មើ ៤៩,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦៨៦,៥លានរៀល។ អនុកម្មវិធីទី ១ នេះសម្រេចលទ្ធផលបាន ៧៧,៧% ក្នុងនោះ៖ (១) សិក្ខាសាលាណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងសិក្ខាសាលាតាមអនឡាញបានចំនួន ១០លើក លើគោលដៅប្រចាំឆ្នាំដែលមានចំនួន ៦លើក ដោយមូលហេតុសិក្ខាសាលាបានរៀបចំតាមអនឡាញនៅខេត្ត ៥ (កំពង់ស្ពឺ, កំពង់ចាម, ព្រះវិហារ, ស្វាយរៀង, និងបាត់ដំបង)។

- **អនុកម្មវិធីទី ២៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី** អនុវត្តបាន ៥០៦,៧ លានរៀល ស្មើ ៥៩,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៨៤៩,៧លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ២៤,៧លានរៀល ស្មើ ៩៥,0% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៦លានរៀល, និងជំពូក ៦១ ចំនួន ៤៨២លានរៀល ស្មើ ៥៨,៥% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៨២៣,៧លានរៀល។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ៩0,0% ក្នុងនោះ៖ សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី, សិក្ខាសាលាគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ, សិក្ខាសាលាពង្រឹងការទូទាត់ថវិកាតាមប្រព័ន្ធ

FMIS បានចំនួន ៥វគ្គ ស្មើ ៧១,០% ធៀបគោលដៅប្រចាំឆ្នាំចំនួន ៧វគ្គ ដោយអនុវត្តនៅ ២៥ រាជធានីខេត្ត។

- **អនុកម្មវិធីទី ៣៖ ការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច** អនុវត្តបាន ១៨៦,២ លានរៀល ស្មើ ៤៣,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៤៧លានរៀល ដោយប្រើថវិកាជំពូក ៦១។ អនុកម្មវិធីទី ៣ នេះសម្រេចលទ្ធផលបាន ៧៣,០% ក្នុងនោះ៖ (១) សិក្ខាសាលាផ្សព្វផ្សាយកិច្ចដំណើរការសវនកម្មផ្ទៃក្នុងនិងពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង, ផ្សព្វផ្សាយនីតិវិធីអធិការកិច្ចរបស់អគ្គាធិការដ្ឋានបានចំនួន ៨៣,០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅខេត្ត ៥ (សៀមរាប, កំពង់ធំ, កំពង់ស្ពឺ, ក្រចេះ, និងត្បូងឃ្មុំ), និង (២) ពង្រឹងប្រតិបត្តិការសវនកម្មផ្ទៃក្នុងបាន ២៦អង្គភាព និងអធិការកិច្ចបាន ៨ ខេត្ត ស្មើ ៨៨,០% ធៀបគោលដៅប្រចាំឆ្នាំ។

- **អនុកម្មវិធីទី ៤៖ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាលនិងយេនឌ័រ** អនុវត្តបាន ១៥១ លានរៀល ស្មើ ៤៣,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៤៧លានរៀល ដោយប្រើថវិកាជំពូក ៦១។ អនុកម្មវិធីទី ៤ នេះសម្រេចលទ្ធផលបាន ៨៩,៣% ក្នុងនោះ៖ (១) សិក្ខាសាលាផ្សព្វផ្សាយស្តីពីទស្សនយេនឌ័រនិងអនុសញ្ញាស៊ី-ដ(CEDAW), សិក្ខាសាលាស្តីពីការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនិងនៅតាមសហគន៍មានអ្នកចូលរួម ៣០០នាក់ ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំដោយអនុវត្តនៅខេត្តមណ្ឌលគិរី, និង (២) សិក្ខាសាលាស្តីពីការងារជនពិការចំនួន ០១លើក, ចុះតាមដានលើកកម្ពស់សិទ្ធិជនពិការតតាមមន្ទីរអភិវឌ្ឍន៍ ៦ខេត្ត ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ។

- **អនុកម្មវិធីទី ៥៖ សេវាគាំទ្រគោលនយោបាយ** អនុវត្តបាន ២០ ១២៨,៦លានរៀល ស្មើ ៨៤,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៣ ៧៨៥,៩លានរៀល ក្នុងនោះជំពូក ៦០ ចំនួន ៣ ៥៤៦,៨លានរៀល ស្មើ ៦៤,៨% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៥ ៤៧០,៦លានរៀល, ជំពូក ៦១ ចំនួន ១ ៩២៧លានរៀល ស្មើ ៤៩,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣ ៨៨៣,៣លានរៀល, ជំពូក ៦៤ ចំនួន ១៤ ៤៨៤,៩លានរៀល ស្មើ ១០១,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៤ ២១៧លានរៀល, និងជំពូក ៦៣ ចំនួន ១៧០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ **អនុកម្មវិធីទី ៥ នេះសម្រេចលទ្ធផលបាន ១០០% ធៀបគោលដៅប្រចាំឆ្នាំ**។

- **អនុកម្មវិធីទី ៦៖** ការពង្រឹងសមត្ថភាពនិងសេវាគាំទ្រដោយមន្ទីរជំនាញរាជធានីខេត្ត អនុវត្តបាន ៣០ ៤៥៤,៧លានរៀល ស្មើ ៩០,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៣ ៧៩២,៦លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ៤ ១១៦,៣លានរៀល ស្មើ ៨៣,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៤ ៩០៧,១លានរៀល, ជំពូក ៦១ ចំនួន ៥ ៨៥៤,៦លានរៀល ស្មើ ៨៦,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦ ៧៨៧,២លានរៀល, ជំពូក ៦៤ ចំនួន ២០ ៤៦០,៨លានរៀល ស្មើ ៩២,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២២ ០៦៤,៣លានរៀល, និងជំពូក ៦៣ ចំនួន ២៣ លានរៀល ស្មើ ៦៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៤លានរៀល។ **អនុកម្មវិធីទី ៦ នេះសម្រេចលទ្ធផលបាន ១០០% ធៀបគោលដៅប្រចាំឆ្នាំ**។

ទន្ទឹមនឹងការសម្រេចបាននូវបណ្តាលទ្ធផលដូចបានបង្ហាញខាងលើ ការអនុវត្តថវិកាឆ្នាំ២០២០ បានជួបការប្រឈមមួយចំនួនដូចខាងក្រោម៖

- ការធ្វើវិចារណកម្មថវិកាចំនួន ២ ដងនៅឆ្នាំ២០២០ ដែលបានធ្វើឲ្យក្រសួងមិនអាចសម្រេចលទ្ធផលតាមការរំពឹងទុកដូចមានក្នុងសូចនាករក្នុងផែនការឆ្នាំ២០២០
- កង្វះគោលនយោបាយច្បាស់លាស់សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង
- សម្ភារៈទទួលបានយកអនុវត្តមានការយឺតយ៉ាវក្រោយពីធ្វើកិច្ចលទ្ធកម្មប្រចាំឆមាស
- ឯកសារទូទាត់ត្រូវបានពន្យាដោយសារតែការបិទខ្ជប់ក្នុងអំឡុងពេលរាលដាលនៃជម្ងឺកូវីដ១៩
- មិនអាចបើកសិក្ខាសាលា ការពិគ្រោះយោបល់ និងបើកវគ្គបណ្តុះបណ្តាលបានដោយផ្ទាល់ដោយត្រូវគោរព
- តាមគោលការណ៍វិធានរបស់រាជរដ្ឋាភិបាលស្តីពីការទប់ស្កាត់ការចម្លងជម្ងឺកូវីដ១៩
- សម្ភារៈសំណង់ ក្រួសក្រហមឡើងថ្លៃនិងពិបាករក ហើយស្ថិតនៅឆ្ងាយៗពីការដ្ឋាន
- ការប្រែប្រួលអាកាសធាតុទាមទារនូវនិរន្តរ៍ និងការចំណាយថវិកាខ្ពស់ក្នុងការអភិវឌ្ឍគម្រោង
- ខ្វះថវិកាសម្រាប់បណ្តុះបណ្តាលនិងចុះតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត មុខងារដែលបានផ្តល់ឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ខ្វះវិធានការទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ពិបាករកទីតាំងសម្រាប់ដីកស្រះ និងខ្ជងអណ្តូង សម្រាប់ប្រើប្រាស់ជាសាធារណៈ
- គណៈកម្មការអភិវឌ្ឍន៍ភូមិពុំមានស្ថាក់ការសម្រាប់ធ្វើការងារ និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យ ឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ។

៣. ២- លទ្ធផល ការប្រឈម និងវិធានការក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣

យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៣ សរណន ចុះថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ បានកំណត់កញ្ចប់ថវិកា ៣ឆ្នាំរំកិល សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទសរុប ចំនួន ៣ ២១៧ ២៦៩លានរៀលក្នុងនោះ៖ ថវិការដ្ឋចំនួន ១ ១៤៤ ២០៧លានរៀល សម្រាប់ឆ្នាំ ២០២២ ចំនួន ៣៦៦ ១២៩លានរៀល, ឆ្នាំ២០២៣ ចំនួន ៣៨១ ៣៣០លានរៀល, ឆ្នាំ២០២៤ ចំនួន ៣៩៦ ៧៤៨លានរៀល, បើធៀបទៅនឹងផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ ដែលមានចំនួន ៩៣៦ ១២៧លានរៀល កញ្ចប់ថវិកា ៣ឆ្នាំរំកិលនេះ មានកំណើន ២២% សម្រាប់រយៈពេល៣ឆ្នាំ ក្នុងនោះឆ្នាំ២០២២ មានកំណើន ១៨% ពីចំនួន ៣១០ ១៣០លានរៀល, ឆ្នាំ២០២៣ មានកំណើន ១៩% ពីចំនួន ៣២០ ៣២៩លានរៀល, និងឆ្នាំ២០២៤ មានកំណើន ២៤% ពីចំនួន ៣២០ ៣២៩

លានរៀល។ ដោយឡែក ថវិការិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ចំនួន ២ ០៧៣ ០៦២ លានរៀល សម្រាប់រយៈពេល ៣ឆ្នាំ ក្នុងនោះ៖ ឆ្នាំ២០២២ ចំនួន ៥៨៨ ១៥៨លានរៀល, ឆ្នាំ២០២៣ ចំនួន ៦៩០ ៦៥៣លានរៀល, និងឆ្នាំ២០២៤ ចំនួន ៧៩៤ ២៥១លានរៀល។

ក. លទ្ធផល និងការប្រឈមក្នុងការអនុវត្តថវិកាឆ្នាំ ២០២១

ក្រសួងអភិវឌ្ឍន៍ជនបទទទួលបានថវិកាឆ្នាំ២០២១ សរុបចំនួន ៣៣៤ ៣៥៥លានរៀល ស្មើ ៨៦,៥% ធៀបច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ដែលមានតែចំនួន ៣៨៦ ៧២៣លានរៀល ដើម្បីបន្តអនុវត្ត គោលនយោបាយនយោបាយលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជនជនបទ ប្រកបដោយបរិយាប័ន្ធទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងបណ្តាគោលនយោបាយតាមអនុវិស័យ និងផ្នែកសំខាន់ៗដូចជា៖ គោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, និងបណ្តាផែនការយុទ្ធសាស្ត្រតាមផ្នែកដទៃទៀត។ ជាលទ្ធផលគិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ ក្រសួងអភិវឌ្ឍន៍ជនបទបានប្រើប្រាស់ថវិការដ្ឋសរុបចំនួន ១១៤ ៨២៦,៣ លានរៀល ស្មើ ៣៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣៣៤ ៣៥៥លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ១ ៩៣៦,១លានរៀល ស្មើ ១៨,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១០ ៦៩៤ លានរៀល, ជំពូក ៦១ ចំនួន ៧ ៣១៣,៣លានរៀល ស្មើ ៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៤១ ១២៩លានរៀល, ជំពូក ៦៤ ចំនួន ១៦ ២១១,៥លានរៀល ស្មើ ៥០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣១ ៨៥៧លានរៀល, ជំពូក ៦៥ ចំនួន ៤១០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ, និងនិងជំពូក ២១ ចំនួន ៨៨ ៩៥៥,៤លានរៀល ស្មើ ៥៩,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៥០ ០០០លានរៀល។ ការអនុវត្តចំណាយខាងលើ ត្រូវបានឆ្លុះបញ្ចាំងទៅតាមកម្មវិធី និងជំពូកដូចខាងក្រោម៖

កម្មវិធីទី ១៖ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ អនុវត្តបាន ៩៤ ០៩៤,១លានរៀល ស្មើ ៣៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៦៧ ៥៩៩ លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ៣៤,១លានរៀល ស្មើ ៥,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦៣៦,៥ លានរៀល, ជំពូក ៦១ ចំនួន ៤ ៨០៤,៦លានរៀល ស្មើ ៤,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១១៦ ៦៦២,៥ លានរៀល, ជំពូក ៦៥ ចំនួន ៣០០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ, និងជំពូក ២១ ចំនួន ៨៨ ៩៥៥,៤លានរៀល ស្មើ ៥៩,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៥០ ០០០ លានរៀល។ **ជាលទ្ធផល គិតត្រឹមពាក់កណ្តាលឆ្នាំ២១ កម្មវិធីទី ១ នេះសម្រេចបាន**ដូចខាងក្រោម៖

- **អនុកម្មវិធីទី ១. ការជួសជុលនិងរក្សាគុណភាពផ្លូវជនបទ** អនុវត្តបាន ១ ៨៨៦,៩លានរៀល ស្មើ ១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១០០ ០២៨,៥លានរៀល ក្នុងនោះ ជំពូក ៦១ ចំនួន ១ ៥៨៦,៩លានរៀល ស្មើ ១,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៩៩ ៤៥១,៩លានរៀល, និងជំពូក៦៥ ចំនួន ៣០០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ អនុកម្មវិធីទី ១ នេះ សម្រេចលទ្ធផលបាន ៤៦% ក្នុងនោះ៖ (១) ថែទាំផ្លូវក្រាលក្រួសក្រហមជាលក្ខណៈខួបបានប្រវែង ៣០១ គ.ម. ស្មើ ៦១,០% ធៀបគោលដៅប្រចាំឆ្នាំប្រវែង ៤៩៣,៨៥គ.ម., និង (២) ថែទាំផ្លូវក្រាលក្រួសក្រហមជា

លក្ខណៈប្រចាំបានប្រវែង ២ ២១៨,០៨ គ.ម. ស្មើ ៦០,០% ធៀបគោលដៅប្រចាំឆ្នាំប្រវែង ៣ ៦៩៧,៧១ គ.ម.។

- **អនុកម្មវិធីទី ២៖ ការពង្រីកវិសាលភាពនៃការស្តាបនាលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ** អនុវត្តបានចំនួន ៨៨ ៩៥៥,៤លានរៀល ស្មើ ៥៩,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៥០ ០០០,០លានរៀល ដោយប្រើថវិកាជំពូក ២១។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ៣២,០% ក្នុងនោះ៖ (១) ផ្លូវក្រាលកៅស៊ូនិងផ្លូវក្រាលបេតុងប្រវែង ៦៦គ.ម. ស្មើ ៣២,០% ធៀបគោលដៅប្រចាំឆ្នាំប្រវែង ១៤៤ គ.ម., និង (២) ផ្លូវក្រាលល្បាយក្រួសប្រវែង ៤៧,៣៨គ.ម. ស្មើ ៤២,០% ធៀបគោលដៅប្រចាំឆ្នាំប្រវែង ១១៤ គ.ម.។

- **អនុកម្មវិធីទី ៣៖ ការរៀបចំបញ្ជីសារពើភ័ណ្ឌនិងមូលដ្ឋានទិន្នន័យផ្លូវជនបទ** ពុំទាន់បានអនុវត្ត

- **អនុកម្មវិធីទី ៤៖ ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទដោយមន្ទីរជំនាញរាជធានីខេត្ត** អនុវត្តបាន ៣ ២៥១,៨លានរៀល ស្មើ ១៩,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៧ ១២៣ លានរៀល ក្នុងនោះជំពូក ៦០ ចំនួន ៣១,៤លានរៀល ស្មើ ១១,២% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣០៣,៤លានរៀល, និងជំពូក ៦១ ចំនួន ៣ ២១៧,៧លានរៀល ស្មើ ១៩,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៦ ៨១៩,៦លានរៀល។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ អនុកម្មវិធីទី ៤ នេះសម្រេចលទ្ធផលបាន ១២,០%។

កម្មវិធីទី ២៖ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ អនុវត្តបាន ៣៦៩,៤លានរៀល ស្មើ ៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១១ ៣៤៧,៦លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ២៣,៤លានរៀល ស្មើ ១៦,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៤៣,៦លានរៀល, ជំពូក ៦១ ចំនួន ២៣៦លានរៀល ស្មើ ២,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១១ ០៩៤លានរៀល, និងជំពូក ៦៥ ចំនួន ១១០លានរៀល ស្មើ ១០០% ធៀបច្បាប់ហិរញ្ញវត្ថុ។ **ជាលទ្ធផល គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ កម្មវិធីទី ២ នេះសម្រេចបាន**ដូចខាងក្រោម៖

- **អនុកម្មវិធីទី ១៖ ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ** ពុំទាន់អនុវត្ត។

- **អនុកម្មវិធីទី ២៖** ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ អនុវត្តបាន ៦៨ លានរៀល ស្មើ ១០,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦៥១លានរៀល ដោយប្រើថវិកាជំពូក ៦៥។ អនុកម្មវិធីទី ២ នេះសម្រេចលទ្ធផលបាន ២៤,០% ក្នុងនោះ៖ (១) សិក្ខាសាលាស្តីពីបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹកចំនួន ៣លើក ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញ, (២) សិក្ខាសាលាស្តីពីការអប់រំប្រជាពលរដ្ឋយល់ដឹងពីការប្រើប្រាស់ទឹកស្អាតបានចំនួន ៣លើក ស្មើ ១០០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តតាកែវ, (៣) សិក្ខាសាលា ៣លើក និងកិច្ចប្រជុំស្តីពីផែនការសុវត្ថិភាពទឹក ៣លើក ស្មើ ៧៩,០% ធៀបគោលដៅប្រចាំឆ្នាំ ដោយអនុវត្តនៅរាជធានីភ្នំពេញនិងខេត្តកំពង់ឆ្នាំង, និង (៤) ចុះតាមដាននិងត្រួតពិនិត្យការងារទឹកស្អាតជនបទបាន ១០០% នៅរាជធានីខេត្ត។

- **អនុកម្មវិធីទី ៣៖ ការស្តាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តអនាម័យជនបទ** ពុំទាន់អនុវត្ត។

- **អនុកម្មវិធីទី ៤៖ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ** អនុវត្ត បាន ៤២លានរៀល ស្មើ ៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៨១៣,៩លានរៀល អនុវត្តក្នុងជំពូក ៦៥។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ អនុកម្មវិធីទី ៤ នេះសម្រេចលទ្ធផលបាន ៨,០% ដោយបានប្រជុំរៀបចំផែនការ បញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ភូមិ/ឃុំ/ស្រុក/ខេត្ត។

- **អនុកម្មវិធីទី ៥៖ ការផ្តល់សេវាសុខភាព និងលក្ខខណ្ឌនៃការរស់នៅសម្រាប់សាធារណៈជនដោយមន្ទីរជំនាញរាជធានី ខេត្ត** អនុវត្តបាន ២៥៩,៤លានរៀល ស្មើ ១៣,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៩៣៩,៩លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ២៣,៤លានរៀល ស្មើ ៣៣,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៧០,១លានរៀល, និងជំពូក ៦១ ចំនួន ២៣៦លានរៀល ស្មើ ១២,៦% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ៨៦៩,៨លានរៀល។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ អនុកម្មវិធីទី ៥ នេះ សម្រេច បាន ១២,០% ធៀបគោលដៅប្រចាំឆ្នាំ។

កម្មវិធីទី ៣៖ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ អនុវត្តបាន ១៣៩,៤លានរៀល ស្មើ ៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣ ៦៦៧,១លានរៀល ក្នុងនោះជំពូក ៦០ ចំនួន ៦៧,៨ លានរៀល ស្មើ ១១,២% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦០៤,១លានរៀល, និងជំពូក ៦១ ចំនួន ៧១,៦លានរៀល ស្មើ ២,៣% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣ ០៦៣លានរៀល។ **ជាលទ្ធផល គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ កម្មវិធីទី ៣ នេះសម្រេចបាន ១៣,០%** ក្នុងនោះ៖

- **អនុកម្មវិធីទី ១៖ ការជំរុញ បង្កើតការងារ និងមុខរបរនៅជនបទ** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ២៖ ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៣៖ ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៤៖ ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ** អនុវត្តបាន ២៧,១ លានរៀល ស្មើ ២,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១ ១៨៩,៦លានរៀល ដោយប្រើថវិកាជំពូក ៦០។
- **អនុកម្មវិធីទី ៥៖ ការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៦៖ ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមជនបទដោយមន្ទីរជំនាញរាជធានី ខេត្ត** អនុវត្តបាន ១១២,២លានរៀល ស្មើ ១៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦១៨,៩ លានរៀល។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ អនុកម្មវិធីទី ៦ នេះសម្រេចបាន ៩,០%។

កម្មវិធីទី ៤៖ ពង្រឹងសេវាគាំទ្ររដ្ឋបាលនិងកិច្ចការទូទៅ អនុវត្តបាន ២០ ២២៣,៥លានរៀល ស្មើ ៣៩,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៥១ ៧៤១,៣លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ១ ៨១០,៨លានរៀល ស្មើ ១៩,៥% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៩ ៣០៩,៨លានរៀល, ជំពូក ៦១ ចំនួន ២ ២០១,១លានរៀល ស្មើ ២១,៤% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១០ ៣០៩,៥លានរៀល, និងជំពូក ៦៤ ចំនួន ១៦ ២១១,៥លានរៀល ស្មើ ៥០,៩% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣១ ៨៥៧លានរៀល។ **ជាលទ្ធផល គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១**

កម្មវិធីទី ៤ នេះសម្រេចបាន ១១,៩៨% ក្នុងនោះ៖

- **អនុកម្មវិធីទី ១៖ ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍជនបទ** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ២៖ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៣៖ ការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៤៖ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល និងយេនឌ័រ** ពុំទាន់អនុវត្ត។
- **អនុកម្មវិធីទី ៥៖ សេវាគាំទ្រគោលនយោបាយ** អនុវត្តបាន ៧ ៧៦១,៤លានរៀល ស្មើ ៣៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២២ ៩៧៦,៤លានរៀល ក្នុងនោះ ជំពូក ៦០ ចំនួន ២២៣លានរៀល ស្មើ ៤,១% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៥ ៣៨៤,៨លានរៀល, ជំពូក ៦១ ចំនួន ១០១,៥លានរៀល ស្មើ ៣,៨% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២ ៧០៤,៦លានរៀល, និងជំពូក ៦៤ ចំនួន ៧ ៤៣៦,៨លានរៀល ស្មើ ៥០,៧% ធៀបច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៤ ៦៧២លានរៀល។ គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១ អនុកម្មវិធីទី ៥ នេះសម្រេចលទ្ធផលបាន ១០,0% ធៀបគោលដៅប្រចាំឆ្នាំ។
- **អនុកម្មវិធីទី ៦.ការពង្រឹងសមត្ថភាពនិងសេវាគាំទ្រដោយមន្ទីរជំនាញរាជធានី ខេត្ត** អនុវត្តបាន ១២ ៤៦២លានរៀល ស្មើ ៤៥,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ២៧ ២៨៥,២លានរៀល ក្នុងនោះ៖ ជំពូក ៦០ ចំនួន ១ ៥៨៧,៨លានរៀល ស្មើ ៤១,6% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៣ ៨១៤,៤លានរៀល, ជំពូក ៦១ ចំនួន ២ ០៩៩,6លានរៀល ស្មើ ៣៣,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ៦ ២៣៥,៨លានរៀល, និងជំពូក ៦៤ ចំនួន ៨ ៧៧៤,៧លានរៀល ស្មើ ៥១,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុដែលមានចំនួន ១៧ ១៨៥លានរៀល។ អនុកម្មវិធីទី ៦ នេះសម្រេចលទ្ធផលបាន ៣១,0% ធៀបគោលដៅប្រចាំឆ្នាំ។

ទន្ទឹមនឹងសម្រេចបាននូវបណ្តាលទ្ធផលដូចបានបង្ហាញខាងលើ ការអនុវត្តផែនការយុទ្ធសាស្ត្រ ថវិកាឆ្នាំ២០២១-២០២៣ បាននិងកំពុងជួបប្រទះការប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរាតត្បាតនៃជំងឺកូវីដ-១៩ បាននិងកំពុងបង្ករការលំបាកដល់កិច្ចប្រតិបត្តិការងារប្រកបដោយប្រសិទ្ធភាពតាមការគ្រោងទុកក្នុងផែនការសកម្មភាពផង និងការតម្រូវឲ្យធ្វើវិចារណកម្មចំណាយដោយកាត់បន្ថយថវិការហូតដល់ ៥0% ផង បាននិងកំពុងប៉ះពាល់ដល់ការសម្រេចតាមគោលដៅនៃសូចនាករនិងគោលបំណងគោលនយោបាយរបស់ក្រសួងផង
- អតុល្យភាពនៃការវិភាជថវិកាសម្រាប់ទ្រទ្រង់ការងារថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍នៅជនបទបាននិងកំពុងបន្តធ្វើឲ្យមានស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពចំណាយទាប
- កង្វះខាតការផ្គត់ផ្គង់វត្ថុធាតុដើមដែលមានគុណភាពសម្រាប់ការសាងសង់ផ្លូវជនបទ បាននិងកំពុងជះឥទ្ធិពលដល់គុណភាពនៃការកសាងនិងជួសជុលផ្លូវជនបទ
- កង្វះវិធានការនិងការចូលរួមប្រកបដោយស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពក្នុងការទប់ស្កាត់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់បាននិងកំពុងបន្តធ្វើឲ្យខាតបង់ផលប្រយោជន៍និងថវិកាសាធារណៈ

- កង្វះគោលនយោបាយសមស្របសម្រាប់រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពគាំទ្រ និងដោះស្រាយបញ្ហាជនបទដែលបាននិងកំពុងមានការវិវត្តយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ន បាននិងកំពុងធ្វើឲ្យមានការលំបាកក្នុងការកាត់បន្ថយគម្លាតរវាងជនបទនិងទីក្រុង
- កង្វះការគាំទ្រថវិកាសម្រាប់ការងារផ្សព្វផ្សាយ, អប់រំ និងបណ្តុះបណ្តាល ដែលជាការងារសំខាន់ និង ចាំបាច់នៅមូលដ្ឋានជនបទបាននិងកំពុងក្លាយជាកត្តារាំងស្ទះដល់ការងារអភិវឌ្ឍន៍ជនបទស្ទើរគ្រប់ផ្នែកនៅក្នុងការងារអភិវឌ្ឍន៍ជនបទ ដែលទាមទារឲ្យមានការយល់ដឹង, គាំទ្រ, ចូលរួម, សហការ, និងធ្វើជាម្ចាស់នៅតាមមូលដ្ឋានជនបទផ្ទាល់ដើម្បីធានាស័ក្តិសិទ្ធិភាព, ប្រសិទ្ធភាព, និងនិរន្តភាពនៃការអភិវឌ្ឍតំបន់ជនបទ
- កង្វះការគាំទ្រថវិកាសម្រាប់បណ្តុះបណ្តាលជំនាញបង្កើតអាជីវកម្មសមស្របនៅមូលដ្ឋាន និងការផ្តល់ឥណទានសម្ព្ធទានសមស្របសម្រាប់ប្រជាជនជនបទបាននិងកំពុងរាំងស្ទះដល់លទ្ធភាពបង្កើនប្រាក់ចំណូលតាមគ្រួសារនិងកាត់បន្ថយចំណាកស្រុក
- កង្វះខាតទីតាំងសម្រាប់ជីកស្រះ និងខួងអណ្តូងសាធារណៈបាននិងកំពុងរាំងស្ទះដល់ការផ្គត់ផ្គង់ទឹកស្អាតនិងទឹកសកិកម្ម
- បម្រែបម្រួលអាកាសធាតុបាននិងកំពុងតែជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរទៅៗដល់ការងារអភិវឌ្ឍន៍ជនបទលើគ្រប់ផ្នែកដែលកាន់តែតម្រូវឲ្យមានការចំណាយខ្ពស់និងមានប្រសិទ្ធភាពទាប
- កង្វះខាតការគាំទ្រនិងកិច្ចសហការពីគ្រប់ភាគីពិសេសនៅតាមមូលដ្ឋានជនបទផ្ទាល់ដូចជាគណៈកម្មការអភិវឌ្ឍន៍ភូមិ/ឃុំ, រដ្ឋបាលថ្នាក់ក្រោមជាតិ, អង្គការដៃគូរអភិវឌ្ឍន៍បាននិងកំពុងធ្វើឲ្យការអនុវត្តគម្រោងអភិវឌ្ឍន៍នានាមានការលំបាកក្នុងការសម្រេចតាមគោលដៅ

២. ផែនការសកម្មភាព និងបណ្តាវិធានការក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣

ដើម្បីបន្តអនុវត្តផែនការសកម្មភាពការងារថវិកាឆ្នាំ២០២១ ក៏ដូចជាបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា២០២១-២០២៣ និងដោះស្រាយនូវបណ្តាការប្រឈមខាងលើក្រសួងអភិវឌ្ឍន៍ជនបទបាននិងកំពុងអនុវត្តនូវផែនការសកម្មភាពនិងបណ្តាវិធានការដូចខាងក្រោម៖

១. បន្តជំរុញការអនុវត្តកម្មវិធីទាំង ០៤ ដែលមានអនុកម្មវិធីចំនួន ២១ និងចង្កោមសកម្មភាពចំនួន១០០ ស្របតាមគោលដៅដែលបានកំណត់ដើមឆ្នាំនិងដោយគោរពតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងបរិការនៃជំងឺកូវីដ-១៩ និងការធ្វើវិចារណកម្មចំណាយតាមរយៈការធ្វើអាទិភាពកម្មលើអាទិភាព។

២. បន្តជំរុញការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ដែលរងការខូចខាតដោយទឹកជំនន់ និងកម្មវិធីសាច់ប្រាក់ពលកម្ម ដើម្បីបង្កើនការតភ្ជាប់និងសម្រួលចរាចរឡើងវិញ ព្រមទាំងផ្តល់ឱកាសឲ្យប្រជាពលរដ្ឋជនបទអាចធ្វើសកម្មភាពជាប្រក្រតីឡើងវិញ និងទទួលបានប្រាក់ចំណូលខ្លះក្នុងស្ថានភាពជំងឺកូវីដ-១៩។ ជាក់ស្តែងគឺជំរុញការងារស្តារ ស្ថាបនា និងជួសជុលហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទដោយថវិការនិយោគរបស់រដ្ឋលើគម្រោងចំនួន ៦៧គម្រោង និងគម្រោងសាច់ប្រាក់

ពលកម្មតាមបណ្តាខេត្តគោលដៅចំនួន ១៨ ដែលមានចំនួន ១ ១៤៩អនុគម្រោងជាកម្រាលដីស និងក្រាលក្រួសក្រហម ចំនួន ២ ៦៧៣អនុគម្រោង។

៣. បន្តពង្រឹងសមត្ថភាពស្ថាប័ន អភិវឌ្ឍធនធានមនុស្ស និងលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈ

- បន្តបញ្ចប់ការរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០, កសាងផែនការរយៈពេលខ្លី រវែង និងមធ្យម, ពង្រឹងការងារគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ, ពិនិត្យ រៀបចំធ្វើវិសោធនកម្មបទដ្ឋានគតិយុត្តនិងធ្វើបច្ចុប្បន្នភាពបទដ្ឋានបច្ចេកទេសការងារសាងសង់ផ្លូវ, បើកវគ្គបណ្តុះបណ្តាលស្តីពីការងារធ្វើតេស្តសម្ភារបរិក្ខារ គ្រឿងសំណង់ និងវត្ថុធាតុដើម នៅមន្ទីរពិសោធន៍, បណ្តុះបណ្តាលការអភិវឌ្ឍជនបទដល់មន្ត្រីថ្នាក់ក្រោមជាតិ, បណ្តុះបណ្តាលចំណេះជំនាញដល់ប្រជាជនជនបទសម្រាប់លើកកម្ពស់ផលិតភាព, រៀបចំចងក្រងគោលការណ៍ណែនាំ បទដ្ឋានបច្ចេកទេស ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្លូវជនបទ ។
- ផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុ, របាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំនិងរបាយការណ៍សវនកម្មជាសាធារណៈលើវេបសាយក្រសួង។
- បង្កើនសកម្មភាពរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពឱ្យមានប្រសិទ្ធភាពខ្ពស់។

៤. បន្តជំរុញការអនុវត្តគម្រោងហិរញ្ញប្បទានថវិកាដៃគូអភិវឌ្ឍន៍ លើគម្រោងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទឆ្នាំ២០២១ ដែលមានចំនួន ១៣គម្រោង ។

៥. បន្តជំរុញការអនុវត្តតាមគោលដៅ ៩០% នៃការផ្គត់ផ្គង់ទឹកស្អាត ការសំអាតនិងអនាម័យ និងគោលដៅនៃការរួចផុតពីការបន្ទោបង់ពាសវាលពាសកាល(ODF)នៅឆ្នាំ២០២៣ នៅខេត្តចំនួន ០៥ (កែប, កំពង់ស្ពឺ, កំពង់ធ្នាំង, ស្វាយរៀង, និងព្រៃវែង)។ បន្តរៀបចំយុទ្ធនាការលើកកម្ពស់អនាម័យជនបទ, ពង្រីកការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យ (Hygiene Promotion), ពង្រឹងនិងពង្រីកកម្មវិធីសហគមន៍ដឹកនាំការងារសម្អាត (Community Led Total Sanitation) នៅតាមបណ្តាខេត្តគោលដៅ, និងការផ្សព្វផ្សាយផែនការសកម្មភាពជាតិជំហានទី២ ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាតនិងអនាម័យជនបទ។

៦. បន្តជំរុញការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ដែលជាការងារចាំបាច់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចជនបទ សំដៅពង្រឹងបង្កើនផលិតភាពកសិកម្ម មុខរបរ ទីផ្សារ និងផ្តល់ធុរៈកិច្ចក្នុង និងក្រៅមូលដ្ឋាន បង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ក្នុងនោះមាន៖

- ការពង្រីកមុខរបរពីការធ្វើស្រែតែមួយមុខទៅជាការអភិវឌ្ឍកសិកម្មចំរុះ,
- ការលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបង្កើតសហគ្រាសខ្នាតគ្រួសារនិងខ្នាតតូច,
- ការបង្កើតការកែច្នៃផលិតផលសហគមន៍,
- ការផ្សព្វផ្សាយនិងការធ្វើពិព័រណ៍ផលិតផលសហគមន៍ “ភូមិខ្ញុំ-ផលិតផលខ្ញុំ”,
- ពង្រឹងនិងពង្រីកគម្រោងឥណទានជនបទ, អភិវឌ្ឍន៍ផ្សារជនបទ។

II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តចក្ខុវិស័យកម្ពុជា និងបណ្តាគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងយុទ្ធសាស្ត្រចតុកោណណាក់កាលទី៤ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍន៍ជនបទជាពីរដំណាក់កាលគឺ "**ការកសាងសង្គមជនបទស៊ីវិលល្អនៅឆ្នាំ២០៣០ និងការកសាងសង្គមជនបទពុទ្ធិនៅឆ្នាំ២០៥០**"។ **សង្គមជនបទស៊ីវិលល្អ** គឺជាសង្គមជនបទមានជីវភាពរស់នៅសមរម្យ មានសុវត្ថិភាព មានផាសុខភាព មានសមធម៌ មានយុត្តិធម៌និងការគោរពច្បាប់ មានជីវិតថ្លៃថ្នូ និងមានភាពធន់។ ជាជនបទដែលមានសេដ្ឋកិច្ចប្រកប ដោយស្វ័យគ្រប់គ្រាន់ គុណ្យភាពការងារនិងជីវិត និងគុណ្យភាពកម្លាំងកាយនិងបញ្ញា និងជាជនបទដែលមាននយោបាយប្រកបដោយសកម្មចូលរួម សមហេតុផ្រេច និងសិទ្ធិសេរីភាពស្មើគ្នាទាំងក្នុងប្រព័ន្ធនយោបាយនិងរដ្ឋបាលសាធារណៈ។ **សង្គមជនបទពុទ្ធិ** គឺជាសង្គមជនបទប្រកបដោយសមត្ថភាព លទ្ធភាព បរិយាប័ន្ន និងចីរភាព។ ជាជនបទដែលមានសេដ្ឋកិច្ចប្រកបដោយសមត្ថភាព សក្តានុពលភាព ផលិតភាព និងការផ្តល់ឱកាសស្មើគ្នា និងជាជនបទដែលមាននយោបាយប្រកបដោយសិទ្ធិសេរីភាពពេញលេញ ប្រជាធិបតេយ្យពេញលេញ និងប្រព័ន្ធយុត្តិធម៌និងការគោរពច្បាប់ពេញលេញទាំងក្នុងប្រព័ន្ធនយោបាយនិងរដ្ឋបាលសាធារណៈ។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ និងដោយផ្អែកលើការសិក្សាស្រាវជ្រាវលើស្ថានភាពភូមិសាស្ត្រ, ប្រជាសាស្ត្រ, សេដ្ឋកិច្ច, ធនធានមនុស្ស, សុខភាពប្រជាជន, សហគមន៍, និងការអភិវឌ្ឍបច្ចុប្បន្ន ព្រមទាំងដោយឈរលើទិដ្ឋភាពសង្គម, សេដ្ឋកិច្ច, នយោបាយ, វប្បធម៌, បរិស្ថាន, បច្ចេកវិទ្យា, និងអភិបាលកិច្ច ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវគោលនយោបាយអាទិភាពពីរគឺគោលនយោបាយ "**លើកកម្ពស់សុខុមាលភាពសង្គមជនបទនិងបង្កើនសុខវឌ្ឍនភាពជនបទ**"។ **ការលើកកម្ពស់សុខុមាលភាព សង្គមជនបទ** មានគោលបំណង ធានាជីវភាពរស់នៅជនបទឲ្យបានសមរម្យ, មានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម, មានផាសុកភាព, មានការគោរពច្បាប់, មានសីលធម៌សង្គម និងមានយុត្តិធម៌សង្គមជាមូលដ្ឋាន ព្រមទាំងមានសមត្ថភាព និងលទ្ធភាពសមស្របជាមូលដ្ឋានក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងមានការការពារធនធានធម្មជាតិក្នុងគោលដៅលើកកម្ពស់កម្រិតជីវភាពរស់នៅប្រជាជនជនបទ, ធ្វើឲ្យប្រសើរឡើងនូវសុខភាព និងលក្ខខណ្ឌរស់នៅជនបទ, និងលើកកម្ពស់គុណតម្លៃជីវិតសហគមន៍ជនបទ។ **ការបង្កើនសុខវឌ្ឍនភាពជនបទ** មានគោលបំណងចាប់យកឱកាសនៃការវិវត្តរបស់សង្គម និងបច្ចេកវិទ្យាដែលកំពុងប្រែប្រួលយ៉ាងខ្លាំង និងដែលកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសការរីកចម្រើននៃបច្ចេកវិទ្យាដែលបាននិងកំពុងវិវត្តយ៉ាងឆាប់រហ័សនាសម័យបច្ចេកវិទ្យាព័ត៌មាន និងកំពុងឆ្ពោះទៅយុគ្គសម័យនៃបដិវត្តន៍ឧស្សាហកម្មទីបួនដើម្បីបង្កើនសុខវឌ្ឍនភាពជនបទប្រកបដោយសុខដុមនីយកម្ម, សមធម៌, បរិយាប័ន្ន, និងចីរភាព សំដៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ ក្នុងគោលដៅបង្កើនការតភ្ជាប់តំបន់ជនបទ, ជំរុញ និងសម្រួល

សកម្មភាពសេដ្ឋកិច្ចនិងសង្គមនៅជនបទ, និងបង្កើនលទ្ធភាព និងសក្តានុពលភាពនៃតំបន់ជនបទដើម្បីប្រែក្លាយជាជនបទប្រកប ដោយសមាហរណកម្ម ព្រមទាំងការអភិវឌ្ឍគោលនយោបាយនិងពង្រឹងអភិបាលកិច្ច ក្នុងគោលដៅបង្កើនស័ក្តិសិទ្ធិភាព, ប្រសិទ្ធភាព, ផលិតភាព, គណនេយ្យភាព, និងតម្លាភាពដើម្បីធានាការអភិវឌ្ឍជនបទប្រកបដោយអភិបាលកិច្ចល្អ។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តរៀបចំនូវបណ្តាគោលនយោបាយតាមផ្នែកសំខាន់ៗមួយចំនួនទៀត សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយគន្លឹះទាំងពីរនេះដែលរួមមានដូចជា គោលនយោបាយផ្លូវជនបទ, គោលនយោបាយទឹកស្អាតនិងអនាម័យជនបទ, គោលនយោបាយអភិវឌ្ឍន៍សហគមន៍ជនបទ, គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស, គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ, និងគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច។

ដើម្បីអនុវត្តគោលនយោបាយខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលបំណងគោលនយោបាយរយៈពេលមធ្យម២០២១-២០២៤ គឺ **"ការកសាងមូលដ្ឋានគ្រឹះសង្គមជនបទស៊ីវិល័យ"** ពោលគឺ**ការកសាងមូលដ្ឋានគ្រឹះនៃសុខមាលភាពនិងសុខវឌ្ឍនភាពសង្គមជនបទ** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤ តាមរយៈការកសាងមូលដ្ឋានគ្រឹះនៃជនបទមានដីវភាពសមរម្យ, មូលដ្ឋានគ្រឹះនៃជនបទមានសុខភាពមាំមួន, មូលដ្ឋានគ្រឹះនៃជនបទមានសហគមន៍ថ្លៃថ្នូរ, មូលដ្ឋានគ្រឹះនៃជនបទមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ដោយសមាហរន្ត, និងមូលដ្ឋានគ្រឹះនៃជនបទមានគោលនយោបាយនិងអភិបាលកិច្ចល្អ ដែលជាគោលដៅដំណាក់កាលទី ១ នៃចក្ខុវិស័យកសាងសង្គមជនបទស៊ីវិល័យឆ្នាំ២០៣០ ។

ការអភិវឌ្ឍជនបទមិនត្រឹមតែជាការងារអភិវឌ្ឍន៍តំបន់ទាំងមូលប្រកបដោយភាពគ្រប់ជ្រុងជ្រោយប៉ុណ្ណោះទេ ថែមទាំងជាការងារមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេសទៀតផង។ ក្នុងន័យនេះ ដើម្បីធានាការអនុវត្តគោលនយោបាយខាងលើប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព ក្រសួងអភិវឌ្ឍន៍ជនបទបានផ្អែកលើភូមិសាស្ត្រ, ប្រជាសាស្ត្រ, សេដ្ឋកិច្ច, ធនធានមនុស្ស, សុខភាពប្រជាជន, សហគមន៍, និងកម្រិតនៃការអភិវឌ្ឍ ព្រមទាំងដោយឈរលើមូលដ្ឋាននៃទិដ្ឋភាពសង្គម, សេដ្ឋកិច្ច, នយោបាយ, វប្បធម៌, បរិស្ថាន, បច្ចេកទេស និងអភិបាលកិច្ច បានបែងចែកប្រទេសកម្ពុជាជា ៥តំបន់យុទ្ធសាស្ត្រគឺ តំបន់១ រួមមានខេត្តកណ្តាល, ខេត្តតាកែវ, ខេត្តស្វាយរៀង, ខេត្តព្រៃវែង ដែលជាតំបន់មានស្ថានភាពសេដ្ឋកិច្ចនិងសង្គមជនបទប្រសើរជាងគេ, តំបន់២ រួមមានខេត្តកំពង់ស្ពឺ, ខេត្តកែប ខេត្តកំពត, ខេត្តព្រះសីហនុ, និងខេត្តកោះកុង ដែលជាតំបន់មានស្ថានភាពសេដ្ឋកិច្ចនិងសង្គមជនបទបង្គួរ, តំបន់ ៣ រួមមានខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ធំ, ខេត្តកំពង់ចាម, ខេត្តត្បូងឃ្មុំ, និងខេត្តក្រចេះ ដែលជាតំបន់មានស្ថានភាពសេដ្ឋកិច្ចនិងសង្គមជនបទមធ្យម, តំបន់៤ រួមមានខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តប៉ៃលិន, ខេត្តបន្ទាយមានជ័យ, និងខេត្តឧត្តរមានជ័យ ដែលជាតំបន់មានស្ថានភាពសេដ្ឋកិច្ចនិងសង្គមជនបទក្រោមមធ្យម, និងតំបន់៥ រួមមានខេត្តព្រះវិហារ, ខេត្តសៀមរាប, ខេត្តស្ទឹងត្រែង, ខេត្តរតនគិរី, និងខេត្តមណ្ឌលគិរី ដែលជាតំបន់មានស្ថានភាពសេដ្ឋកិច្ចនិងសង្គមជនបទលំបាកជាងគេ។

ទន្ទឹមនេះ ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទខាងលើ ត្រូវបានផ្អែកលើយុទ្ធសាស្ត្របច្ចេកទេសចំនួន១១ដូចខាងក្រោម៖

១. យុទ្ធសាស្ត្រពហុវិស័យ គឺជាមូលដ្ឋានបច្ចេកទេសដ៏សំខាន់ និងចាំបាច់ក្នុងការងារអភិវឌ្ឍន៍ជនបទដែលតម្រូវឲ្យមានសមាសភាគពហុជំនាញដើម្បីអាចដោះស្រាយបញ្ហា និងការប្រឈមនានានៅក្នុងតំបន់ជនបទទាំងមូលព្រោះការងារអភិវឌ្ឍជនបទគឺជាការងារអភិវឌ្ឍន៍សហគមន៍ ឬសង្គមជនបទទាំងមូល។

២. យុទ្ធសាស្ត្រអភិក្រមចម្រុះ គឺជាមូលដ្ឋានឧបាយសិល្ប:ដ៏សំខាន់ និងចាំបាច់មិនអាចខ្វះបានក្នុងការងារអភិវឌ្ឍន៍ជនបទដែលតម្រូវឲ្យមានការយល់ដឹង និងដកពិសោធន៍ជាក់ស្តែងទៅតាមតំបន់ជនបទមួយៗដើម្បីអាចឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាក់ស្តែង នៃតំបន់នីមួយៗប្រកបដោយស័ក្ដិសិទ្ធិភាព ប្រសិទ្ធភាព និងផលិតភាពខ្ពស់។

៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាំងរឹង និងទន់ គឺជាតម្រូវការនៃសង្គមទាំងមូលដែលមិនអាចខ្វះបានពោលគឺទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្តដែលត្រូវធានាឲ្យមានការអភិវឌ្ឍប្រកបដោយ គុណ្យភាពសមស្របដើម្បីធានាការអភិវឌ្ឍប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រសិទ្ធភាពខ្ពស់។

៤. យុទ្ធសាស្ត្រពង្រឹង និងបង្កើនការតភ្ជាប់ជាប្រព័ន្ធទាំងក្នុងតំបន់ជនបទ និងរវាងតំបន់ជនបទ និងទីក្រុង គឺជាភាពចាំបាច់ក្នុងការតភ្ជាប់បណ្ដាញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ទាំងក្នុងតំបន់ជនបទ និងរវាងតំបន់ជនបទ ជាពិសេសរវាងតំបន់ជនបទ និងទីក្រុងដើម្បីធានាការទទួលបាននូវអត្ថប្រយោជន៍ អតិបរិមាពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ។

៥. យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន គឺជាគន្លឹះនៃអភិបាលកិច្ចក្នុងការងារអភិវឌ្ឍន៍ជនបទដើម្បីធានាការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីអាទិភាពនានាប្រកបដោយស័ក្ដិសិទ្ធភាព, ប្រសិទ្ធភាព, ផលិតភាព, គណនេយ្យភាព, និងតម្លាភាព។

៦. យុទ្ធសាស្ត្រប្រជាសាស្ត្រ គឺជាមូលដ្ឋានសង្គមដ៏សំខាន់ និងចាំបាច់បំផុតដែលមិនអាចមើលរំលង និងខ្វះការយកចិត្តទុកដាក់បាន ពិសេសការយកចិត្តទុកដាក់លើមនុស្សពេញវ័យក្នុងសហគមន៍ជនបទដែលជាកម្លាំងពលកម្មសំខាន់ និងចាំបាច់របស់សហគមន៍ និងមនុស្សចាស់ដែលសង្គមត្រូវការថែទាំគាំពារ។

៧. យុទ្ធសាស្ត្រសម្រាប់ស្ត្រី កុមារ និងបញ្ហាយេនឌ័រ គឺជាបញ្ហាសំខាន់ និងចាំបាច់ក្នុងការងារអភិវឌ្ឍន៍ជនបទ ព្រោះជាក្រុមទន់ខ្សោយ និងងាយរងគ្រោះ និងជាប្រភពនៃភាពក្រីក្រ ព្រមទាំងជាធនធានដែលភាគច្រើនខ្វះលទ្ធភាព ខ្វះសមត្ថភាព និងទទួលបានឱកាសតិចជាងគេនៅជនបទ។

៨. យុទ្ធសាស្ត្រធានាសមធម៌ និងបរិយាប័ន្ន គឺគួរតែជាគោលការណ៍ចម្បងក្នុងការងារអភិវឌ្ឍន៍ជនបទ ព្រោះការអភិវឌ្ឍជនបទដោយគ្មានសមធម៌ និងបរិយាប័ន្នគឺមិនត្រឹមតែមិនអាចដោះស្រាយបញ្ហាបានប៉ុណ្ណោះទេ ថែមទាំងជាប្រភពបង្កើតអតុល្យភាពកំណើន និងការអភិវឌ្ឍព្រមទាំងគម្លាតចំណូល និងវិសមភាព សង្គមកាន់តែខ្លាំងនៅជនបទ។

៩. យុទ្ធសាស្ត្រធានាចីរភាព គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាននៅក្នុងសមីការនៃការអភិវឌ្ឍជនបទ ដើម្បីធានានិរន្តរភាព និងស្ថិរភាពនៃការអភិវឌ្ឍនៅជនបទ។

១០. យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្ស គឺជាមុខពីរនៃកាក់តែមួយដែលត្រូវតែយកចិត្តទុកដាក់ឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីរក្សាតុល្យភាព ពិសេសរវាងវប្បធម៌ប្រពៃណីបុរាណ និងការធ្វើទំនើបកម្មប្រកបដោយគុណធម៌ និងសុខដុមនីយកម្ម។

១១. យុទ្ធសាស្ត្រលើកកម្ពស់ និងជំរុញកិច្ចសហប្រតិបត្តិការ គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានក្នុងការងារអភិវឌ្ឍន៍ជនបទដែលទាមទារឲ្យមានការចូលរួមគាំទ្រ និងកិច្ចសហការពីគ្រប់តួអង្គនៃសង្គម ជាពិសេសការចូលរួមប្រកបដោយភាពជាម្ចាស់របស់សហគមន៍ ជនបទដើម្បីធានាស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ផលិតភាព សុខដុមនីយកម្ម ចីរភាព និងជោគជ័យក្នុងការងារអភិវឌ្ឍន៍ជនបទ។

ជាក់ស្តែងគោលនយោបាយទាំងពីរខាងលើ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដូចខាងក្រោម៖

<u>តារាងទី១ ទំនាក់ទំនងគោលនយោបាយរបស់ក្រសួង</u>

គោលបំណងគោលនយោបាយ	**ទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៩-២០២៣**	**ទំនាក់ទំនងទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**
គោលនយោបាយទី១៖ ការលើកកម្ពស់សុខុមាលភាពសង្គមជនបទ	យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី៤ មុំទី១ការលើកកម្ពស់កសិកម្មនិងការអភិវឌ្ឍជនបទ ចតុកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច មុំទី១ ការកែលម្អប្រព័ន្ធឡូជីស្ទីកលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល	បង្កើតការងារ សហគ្រាស និងមុខរបរ បរិស្ថាន និងការប្រែប្រួល អាកាសធាតុ
គោលនយោបាយទី ២៖ ការបង្កើនសុខវឌ្ឍនភាពសង្គមជនបទ	ចតុកោណទី៣ ការលើកស្ទួយវិស័យ ឯកជន និងការងារ ចតុកោណទី១ ការអភិវឌ្ឍធនធានមនុស្ស	ហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ផ្នែកដឹកជញ្ជូន អភិវឌ្ឍន៍ធនធានមនុស្ស ពង្រឹង សមត្ថភាព

III. ការរៀបចំកម្មវិធីសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២២-២០២៤

ដើម្បីសម្រេចបានតាមគោលបំណងគោលនយោបាយរយៈពេលមធ្យម នៃគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០ ពិសេសការកសាងមូលដ្ឋានគ្រឹះនៃសង្គមជនបទ ស៊ីវិល័យ ដែលជាដំណាក់កាលទី១ នៃការចាប់ផ្តើមអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ពោលគឺការ**ការកសាងមូលដ្ឋានគ្រឹះនៃសុខមាលភាពនិងសុខវឌ្ឍនភាពសង្គមជនបទ** តាមរយៈការកសាងមូលដ្ឋានគ្រឹះនៃជនបទមានជីវភាពសមរម្យ មូលដ្ឋានគ្រឹះនៃជនបទមានសុខភាពមាំមួន មូលដ្ឋានគ្រឹះនៃជនបទមានសហគមន៍ថ្លៃថ្នូរ មូលដ្ឋានគ្រឹះនៃជនបទសមាហរណ និងមូលដ្ឋានគ្រឹះនៃគោលនយោបាយត្រឹមត្រូវនិងអភិបាលកិច្ចល្អ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំកម្មវិធីចំនួន ៥ ដែលមានទំនាក់ទំនងទៅនឹងគោលនយោបាយ និងចក្ខុវិស័យដូចមានបង្ហាញក្នុងដ្យាក្រាមខាងក្រោម៖



កម្មវិធីទាំងប្រាំខាងលើមានគោលបំណងដូចខាងក្រោម៖

គោលបំណងកម្មវិធីទី១ ៖ បង្កើនប្រាក់ចំណូលរបស់ប្រជាជនជនបទតាមរយៈការអភិវឌ្ឍវិស័យកសិកម្មជនបទ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ អភិវឌ្ឍន៍ទីផ្សារជនបទនិងអភិវឌ្ឍន៍គោល

នយោបាយនិងពង្រឹងអភិបាលកិច្ច។

គោលបំណងកម្មវិធីទី២ ៖ បង្កើនសុខុមាលភាពសង្គមជនបទតាមរយៈការអភិវឌ្ឍធនធានមនុស្ស ជនបទ ថែទាំនិងលើកកម្ពស់សុខភាពជនបទ ថែទាំនិងបង្កើនសក្តានុពលធនធានធម្មជាតិជនបទ និងអភិវឌ្ឍន៍ គោលនយោបាយ និងអភិបាលកិច្ចគោលដៅបង្កើនសុខភាពមាំមួនជូនប្រជាជនជនបទ។

គោលបំណងកម្មវិធីទី៣ ៖ កសាងសហគមន៍ជនបទធានាឲ្យបានសុខសន្តិភាព និងសុវត្ថិភាពជូនប្រជាជន អភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសហគមន៍ជនបទ អភិវឌ្ឍន៍គុណតម្លៃសហគមន៍ជនបទ និងអភិវឌ្ឍន៍គោលនយោបាយនិងពង្រឹងអភិបាលកិច្ចក្នុងសហគមន៍ជនបទ។

គោលបំណងកម្មវិធីទី៤ ៖ បង្កើនការតភ្ជាប់តំបន់ជនបទទាំងក្នុងសហគមន៍ និងរវាងទីជនបទ និងទីប្រជុំជន ទីក្រុង តាមរយៈសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងគមនាគមន៍ជនបទ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រខ្នាតតូចរួមមាន ប្រឡាយស្រោចស្រពខ្នាតតូច ប្រឡាយរំដោះទឹក ទំនប់ទឹកខ្នាតតូចក្នុងសហគមន៍ អភិវឌ្ឍន៍ប្រព័ន្ធថាមពលកកើតឡើងវិញដូចជាបំពាក់ម៉ាស៊ីនបូមទឹក ស្រោចស្រពដោយប្រើថាមពលសឡា ថាមពលខ្យល ក្នុងគោលដៅប្រើប្រាស់ក្នុងសហគមន៍ បម្រើជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅតំបន់ដាច់ស្រយ៉ាល ដែលពុំទាន់មានថាមពលអគ្គិសនីទៅដល់។

គោលបំណងកម្មវិធីទី៥ ៖ ធានាឲ្យមានគោលនយោបាយរយៈពេលវែងមួយសមស្របអាចអនុវត្តបានដោះ ស្រាយបានរាល់បញ្ហា ការប្រឈម និងតម្រូវការនៅតំបន់ជនបទ តាមរយៈការរៀបចំ ការអនុវត្ត ថវិកាប្រកបដោយប្រសិទ្ធភាព ដោយតម្លាភាព គណនេយ្យភាព ដោយមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ តាមដំណាក់កាលៗនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិឆ្នាំ២០២១-២០៣០ ព្រមទាំងកសាងឲ្យបានគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស និងពង្រឹងស្ថាប័ន ។

កម្មវិធីទាំងប្រាំខាងលើ ត្រូវបានរៀបចំជាអនុកម្មវិធីចំនួន ២២ និងការរួមចំណែកអនុវត្តដោយរាជធានីខេត្តទៅតាមគោលបំណងនៃកម្មវិធីនីមួយៗដូចខាងក្រោម៖

កម្មវិធីទី ១. ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ

- អនុកម្មវិធីទី១. ការអភិវឌ្ឍកសិកម្មជនបទ ផ្តោតលើក្សេត្រាជីវកម្ម
- អនុកម្មវិធីទី២. ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ
- អនុកម្មវិធីទី៣. ការអភិវឌ្ឍទីផ្សារជនបទ
- អនុកម្មវិធីទី៤. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច
- ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយមន្ទីររាជធានីខេត្ត

កម្មវិធីទី ២. ការអភិវឌ្ឍសុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ

- អនុកម្មវិធីទី១. ការអភិវឌ្ឍទឹកស្អាតជនបទ
- អនុកម្មវិធីទី២. ការអភិវឌ្ឍអនាម័យជនបទ
- អនុកម្មវិធីទី៣. ការលើកកម្ពស់បរិស្ថានជនបទ
- អនុកម្មវិធីទី៤. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច
- ការអភិវឌ្ឍសុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ ដោយមន្ទីររាជធានីខេត្ត

កម្មវិធីទី ៣. ការអភិវឌ្ឍសហគមន៍ជនបទ

- អនុកម្មវិធីទី១. ការរក្សាសន្តិសុខ និងសុវត្ថិភាពសហគមន៍ជនបទ
- អនុកម្មវិធីទី២. អភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសហគមន៍ជនបទ
- អនុកម្មវិធីទី៣. ការអភិវឌ្ឍគុណតម្លៃសហគមន៍ជនបទ
- អនុកម្មវិធីទី៤. អភិរក្ស និងអភិវឌ្ឍន៍ជាតិដើមភាគតិច
- អនុកម្មវិធីទី៥. ការអភិវឌ្ឍធនធានមនុស្សជនបទ
- អនុកម្មវិធីទី៦. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច
- ការអភិវឌ្ឍសហគមន៍ជនបទ ដោយមន្ទីរាជធានីខេត្ត

កម្មវិធីទី ៤. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ

- អនុកម្មវិធីទី១. ការអភិវឌ្ឍផ្លូវជនបទ និងសំណង់សិល្បការ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ
- អនុកម្មវិធីទី២. ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពកសិកម្មខ្នាតតូចជនបទ
- អនុកម្មវិធីទី៣. ការអភិវឌ្ឍថាមពលកកើតឡើងវិញនៅតំបន់ជនបទ
- អនុកម្មវិធីទី៤. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច
- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ ដោយមន្ទីរាជធានីខេត្ត

កម្មវិធីទី ៥. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច

- អនុកម្មវិធីទី១. ពង្រឹងការកសាងគោលនយោបាយ និងថវិកានីយកម្ម
- អនុកម្មវិធីទី២. ពង្រឹងការគ្រប់គ្រងធនធាន និងការអនុវត្តថវិកា
- អនុកម្មវិធីទី៣. ពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម
- អនុកម្មវិធីទី៤. ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច ដោយមន្ទីរាជធានីខេត្ត

រចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ត្រូវបានបែងចែកការគ្រប់គ្រង និងការទទួលខុសត្រូវទៅតាមប្រធានកម្មវិធីនិងអង្គភាពប្រតិបត្តិដូចមានបង្ហាញក្នុងតារាងឧបសម្ព័ន្ធ១។

IV. ការរៀបចំសូចនាករគោល និងគោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ **សង្គមជនបទស៊ីវិល័យឆ្នាំ២០៣០** ក្រសួងបានកំណត់សូចនាការគោលនិងគោលដៅ ទៅតាមយុទ្ធសាស្ត្រ៣ដំណាក់កាលដូចខាងក្រោម៖

ដំណាក់កាលទីមួយ ៖ កសាងមូលដ្ឋានគ្រឹះជនបទស៊ីវិល័យឆ្នាំ២០២១-២០៣០ ដោយបានកំណត់គោលដៅចំនួន ៥ គឺ កសាងមូលដ្ឋានគ្រឹះនៃជីវភាពសមរម្យ, ពង្រឹងមូលដ្ឋានគ្រឹះនៃសុខភាពមាំមួន, កសាងមូលដ្ឋានគ្រឹះនៃសហគមន៍ថ្លៃថ្នូរ, កសាងមូលដ្ឋានគ្រឹះនៃជនបទសមាហរណ, និង (៥)ពង្រឹងមូលដ្ឋានគ្រឹះនៃស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃគោលនយោបាយនិងអភិបាលកិច្ចល្អ។ គោលដៅដំណាក់កាលទី១ នេះយ៉ាងហោចសម្រេចឲ្យបាន ៣០% នៃសង្គមជនបទស៊ីវិល័យនៅឆ្នាំ២០២៣ ដែលជាមូលដ្ឋានគ្រឹះឈានទៅកសាងសង្គមជនបទស៊ីវិល័យនៅឆ្នាំ២០២៤។

ដំណាក់កាលទីពីរ៖ សាងសង់សង្គមជនបទស៊ីវិល័យឆ្នាំ២០២៤-២០២៨ ដោយបានកំណត់គោលដៅចំនួន ៥ គឺ សាងសង់ជីវភាពសមរម្យ, សាងសង់សុខភាពមាំមួន, សាងសង់សហគមន៍ថ្លៃថ្នូរ, សាងសង់ជនបទសមាហរណ, និងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃគោលនយោបាយ និងអភិបាលកិច្ចល្អ។ គោលដៅដំណាក់កាលទី២ នេះគឺសម្រេចឲ្យបានយ៉ាងតិច ៨០% នៃសង្គមជនបទស៊ីវិល័យនៅឆ្នាំ២០២៨ ដើម្បីឈានទៅបញ្ចប់ការកសាងសង្គមជនបទស៊ីវិល័យនៅឆ្នាំ២០៣០។

ដំណាក់កាលទី៣៖ បំពេញបន្ថែម និងរក្សានិរន្តរភាពសង្គមជនបទស៊ីវិល័យឆ្នាំ២០២៩-២០៣០ ដែលជាដំណាក់កាលបញ្ចប់ និងរក្សានិរន្តរភាពនៃការកសាងសង្គមជនបទស៊ីវិល័យ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានជីវភាពរស់នៅសមរម្យប្រកបដោយគុណតម្លៃ, មានសុខភាពមាំមួន និងបរិស្ថានរស់នៅល្អផាសុខភាព, មានសហគមន៍រស់នៅថ្លៃថ្នូរ និងប្រកបដោយសុវត្ថិភាព, សន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរស់នៅចេះជួយគ្នាទៅវិញទៅមក និងមានការគោរពច្បាប់ក្រោមប្រព័ន្ធយុត្តិធម៌និងនីតិរដ្ឋ, មានជីវិតរស់នៅប្រកបដោយវប្បធម៌, គោរពប្រពៃណី, សាសនា, និងអត្តសញ្ញាណជាតិដោយសុខដុមរមនីយកម្ម និងមានភាពធន់ទៅនឹងបរិស្ថានធម្មជាតិ, មានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមាហរណ, និងមានគោលនយោបាយនិងអភិបាលកិច្ចល្អក្នុងការងារអភិវឌ្ឍន៍សង្គមជនបទ។

សូចនាការគោល និងគោលដៅតាមកម្មវិធី, អនុកម្មវិធី, និងទៅតាមឆ្នាំនីមួយៗមានបង្ហាញលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ២។

តារាងទី២៖ សូចនាករគោល និងគោលដៅតាមកម្មវិធីសម្រាប់រយៈពេលមធ្យម

កម្មវិធី	សូចនាករគោល/គោលដៅសម្រាប់ ឆ្នាំ២០២២-២០២៤
កម្មវិធីទី១៖ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ	**មូលដ្ឋានគ្រឹះជីវភាពសមរម្យនៅជនបទត្រូវបានកសាង** ១. ចំណូលបុគ្គលម្នាក់ប្រចាំឆ្នាំ $១ ៧៥០ ២. ៥០% មានការងារសមរម្យ (*) ៣. ៥០% មានទីផ្សារសមស្រប
កម្មវិធីទី២៖ការអភិវឌ្ឍសុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ	**មូលដ្ឋានគ្រឹះសុខភាពមាំមួននៅជនបទត្រូវបានកសាង** ១. ៨០% មានទឹកស្អាត និង ៥០% ប្រើប្រាស់ដោយសុវត្ថិភាព ២. ៨០% មានបង្គន់ និង ៦០% មានអនាម័យ ៣. ៥០% មិនបន្ទោបង់ពាសវាល និង ៣០% មានបរិស្ថានល្អ
កម្មវិធីទី៣៖ការអភិវឌ្ឍសហគមន៍ជនបទ	**មូលដ្ឋានគ្រឹះសហគមន៍ថ្លៃថ្នូរនៅជនបទត្រូវបានកសាង** ១. ៣០% អត្រាមានគោលការណ៍សមស្រប ២. ៣០% អត្រាសហគមន៍/ភូមិគំរូ ៣. ៣០% អត្រាគោរពសមូហភាពម្លៃស្នូល
កម្មវិធីទី៤៖ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ	**មូលដ្ឋានគ្រឹះជនបទសមាហរណកម្មត្រូវបានកសាង** ១. ៦០% ត្រូវបានតភ្ជាប់ និង ៣០% មានគុណភាព ២. ៥០% មានទឹកកសិកម្មជនបទ ៣. ៨០% មានថាមពលជនបទ
កម្មវិធីទី៥៖ការអភិវឌ្ឍគោលនយោបាយ និងអភិបាលកិច្ច	**មូលដ្ឋានគ្រឹះគោលនយោបាយនិងអភិបាលកិច្ចល្អត្រូវបានកសាង** ១. មានគោលនយោបាយ, យុទ្ធសាស្ត្រ, កម្មវិធី, វិភាជន៍ថវិកា, និងការដឹកនាំសមស្រប ២. មានគោលការណ៍, នីតិវិធី, និងគ្រប់គ្រងធនធាន និងការអនុវត្តថវិកាសមស្រប ៣. មានការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃសមស្រប

តារាងទី៣ៈ សូចនាករគោល និងគោលដៅតាមអនុកម្មវិធីសម្រាប់រយៈពេលមធ្យម

កម្មវិធីទី ១ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ		
គោលបំណងអនុកម្មវិធី	**សូចនាករគោល**	**គោលដៅ**
កសាងមូលដ្ឋានគ្រឹះជីវភាពសមរម្យ ១. ការអភិវឌ្ឍកសិកម្មជនបទផ្តោតលើក្សេត្រជីវកម្ម ២. ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ៣. ការអភិវឌ្ឍទីផ្សារជនបទ ៤. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច ៥.ការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមគ្រួសារនៅជនបទដោយមន្ទីររាជធានីខេត្ត	១. ១. កំណើនទិន្នផលស្រូវនៅជនបទ ១. ២. កំណើនចំណូលពីរបរកសិកម្ម ២. ១. អត្រាសហគ្រិនជនបទ ២. ២. អត្រាចំណូលក្រៅពីរបរកសិកម្ម ៣. ១. អត្រាទីផ្សារទំនិញ និងសេវាជនបទសមស្រប ៣. ២. អត្រាទីផ្សារទុនជនបទសមស្រប ៤. ១. មានគោលនយោបាយ, យុទ្ធសាស្ត្រ, សកម្មភាព, វិភាជន៍ថវិកា, និងដឹកនាំសមស្រប ៤. ២. មានគោលការណ៍, នីតិវិធី, និងគ្រប់គ្រងធនធាន និងអនុវត្តថវិកាសមស្រប ៤. ៣. មានការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃសមស្រប ៥.១. រួមចំណែកជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារនីមួយៗនៅតាមតំបន់ជនបទ ៥.២.ចលនាឲ្យប្រជាជនជនបទចូលរួមអនុវត្តកម្មវិធីនេះដោយស្ម័គ្រចិត្ត	១.៥ - ២.៥តោន/ហិកតា ៩៥០ - ១ ២៥០ដុល្លារ/ឆ្នាំ យ៉ាងតិច ៣០% យ៉ាងតិច ២០% យ៉ាងតិច ៥០% យ៉ាងតិច ៣០% - គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងឥណទានជនបទសមស្រប - វិភាជន៍ និងអនុវត្តថវិកាសមស្រប - តាមដានត្រួតពិនិត្យ និងវាយតម្លៃសមស្របអោយបាន៥0% -តាមភូមិនិមួយៗក្នុងតំបន់ទាំង៥
កម្មវិធីទី ២ ការអភិវឌ្ឍសុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ		
គោលបំណងអនុកម្មវិធី	**សូចនាករគោល**	**គោលដៅ**
កសាងមូលដ្ឋានគ្រឹះសុខភាពមាំមួន ១. ការអភិវឌ្ឍទឹកស្អាតជនបទ ២. ការអភិវឌ្ឍអនាម័យជនបទ ៣. លើកកម្ពស់បរិស្ថានជនបទ ៤. លើកកម្ពស់អភិបាលកិច្ចការកសាងមូលដ្ឋានគ្រឹះសុខភាពមាំមួន ៥.ការផ្តល់សេវាសុខភាពនិងលក្ខខណ្ឌរស់នៃការរស់នៅសម្រាប់សាធារណៈជនដោយមន្ទីរាជធានីខេត្ត	១. ១. ជនបទមានទឹកស្អាត ១. ២. ជនបទប្រើប្រាស់ទឹកស្អាតដោយសុវត្ថិភាព ២. ១. ជនបទមានបង្គន់អនាម័យ ២. ២. ជនបទប្រើប្រាស់បង្គន់ដោយអនាម័យ ៣. ១. អត្រាគ្មានការបន្ទោបង់ពាសវាលនៅជនបទ ៣.២. អត្រាជនបទមានបរិស្ថានរស់នៅល្អ ៤. ១. គោលនយោបាយ, យុទ្ធសាស្ត្រ, សកម្មភាព,វិភាជន៍ថវិកា, និងដឹកនាំសមស្រប	៦0% - ៨0% យ៉ាងតិច ៥0% ៥0% - ៨0% យ៉ាងតិច ៦0% យ៉ាងតិច ៥0% យ៉ាងតិច ៥0% - គោលនយោបាយទឹក, អនាម័យ, និងបរិស្ថានរស់នៅជនបទ - វិភាជន៍និងអនុវត្តថវិកាសមស្រប - តាមដានត្រួតពិនិត្យនិងវាយតម្លៃសមស្រប - រួមចំណែកសម្រេចគោលដៅខាងលើ

	៤. ២. មានគោលការណ៍, នីតិវិធី, និងគ្រប់គ្រងធនធាននិងអនុវត្តថវិកាសមស្រប ៤. ៣. មានការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃសមស្រប ៥.១. ចូលរួមប្រតិបត្តិសេវាទឹកស្អាត និងអនាម័យ ដោយផ្ទាល់ដើម្បីសម្រេចគោលដៅ	
កម្មវិធីទី ៣. ការអភិវឌ្ឍសហគមន៍ជនបទ		
គោលបំណងអនុកម្មវិធី	**សូចនាករគោល**	**គោលដៅ**
កសាងមូលដ្ឋានគ្រឹះសហគមន៍ថ្លៃថ្នូរ ១. ការការពារសន្តិសុខ និងសុវត្ថិភាពសហគមន៍ជនបទ ២. អភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសហគមន៍ជនបទ ៣. ការអភិវឌ្ឍគុណតម្លៃសហគមន៍ជនបទ ៤. ការអភិវឌ្ឍធនធានមនុស្សជនបទ ៥.អភិរក្ស និងអភិវឌ្ឍន៍ជាតិដើមភាគតិច ៦. ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច ៧.អភិវឌ្ឍន៍សហគមន៍មូលដ្ឋានជនបទដោយមន្ទីររាជធានីខេត្ត	១. ១. មានក្របខ័ណ្ឌគតិយុត្ត និងរចនាសម្ព័ន្ធស្ថាប័នធានាសន្តិសុខសណ្តាប់ធ្នាប់សហគមន៍ ១. ២. មានការចូលរួមការពារសន្តិសុខសណ្តាប់ធ្នាប់សហគមន៍សមស្រប ១. ៣. បទល្មើស (គ្រឿងញៀន-ល្បែង-លួចឆក់-អំពើហឹង្សា) ២. ១. មានក្របខ័ណ្ឌគតិយុត្ត និងរចនាសម្ព័ន្ធស្ថាប័នធានាការគាំពារ និងសំណាញ់សុវត្ថិភាពសហគមន៍ ២. ២. អត្រាភូមិមានប្រព័ន្ធគាំពារ និងសំណាញ់សុវត្ថិភាពសហគមន៍ជាមូលដ្ឋាន ២. ៣. អត្រាប្រជាជនជនបទទទួលបានការគាំពារ ៣. ១. អត្រាភូមិមានគោលការណ៍តម្លៃស្នូលសហគមន៍ ៣. ២. ចំនួនសហគមន៍/ភូមិគំរូ ៣. ៣. អត្រាគោរពសមូហភាពតម្លៃស្នូលសហគមន៍ ៤. ១. អត្រាអនក្ខរជន និងអត្រាចប់បឋមសិក្សា ៤. ២. អត្រាចប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ៤. ៣. អត្រាមានសញ្ញាបត្រជំនាញ ៥.១. ជនជាតិដើមភាគតិចត្រូវបានអភិវឌ្ឍន៍ និងអភិរក្សជាសម្បត្តិជាតិ ៦. ១. គោលនយោបាយ, យុទ្ធសាស្ត្រ, សកម្មភាព,វិភាជន៍ថវិកា, និងដឹកនាំសមស្រប	៣០% - ៥០% ៣០% - ៥០% មិនលើសពី ១៥ករណី/ឆ្នាំ/ភូមិ ១០% -៥០% ៣០% ៣០% ២០%/២២% - ១៥%/៣០% ១០%/៤% - ២០%/១០% យ៉ាងតិច ១០% យ៉ាងតិច ៣០% យ៉ាងតិច ១ នៅគ្រប់ខេត្ត យ៉ាងតិច ៣០% - គោលនយោបាយគាំពារសហគមន៍ជនបទ និងគុណតម្លៃសហគមន៍ជនបទ (ភូមិគំរូនិងជនជាតិដើម) - វិភាជន៍និងអនុវត្តថវិកាសមស្រប - តាមដានត្រួតពិនិត្យនិងវាយតម្លៃសមស្រប - គ្រប់ភូមិក្នុងតំបន់ទាំង៥

	៦. ២. មានគោលការណ៍, នីតិវិធី, និងគ្រប់គ្រងធនធាននិងអនុវត្តថវិកាសមស្រប ៦. ៣. មានការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃសមស្រប ៧.១.ជំរុញលើកទឹកចិត្តឲ្យសហគមន៍ចូលរួមអនុវត្ត ៧.២.បង្កើនជំនឿជាក់របស់ប្រជាជនមកលើរាជរដ្ឋាភិបាល	
កម្មវិធីទី ៤. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ		
គោលបំណងអនុកម្មវិធី	**សូចនាករគោល**	**គោលដៅ**
កសាងមូលដ្ឋានគ្រឹះជនបទ **សមាហរណ** ១. ការអភិវឌ្ឍផ្លូវជនបទ និងសំណង់សិល្បការៈដែលធន់នឹងការប្រែប្រួលអាកាសធាតុ ២. ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពកសិកម្មខ្នាតតូចជនបទ ៣. ការអភិវឌ្ឍថាមពលកកើតឡើងវិញនៅតំបន់ជនបទ ៤.ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច ៥.ការចូលរួមថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទដោយមន្ទីររាជធានី ខេត្ត ចំនួន២៥	១. ១. អត្រាតភ្ជាប់តំបន់ជនបទ (ជាមូលដ្ឋាន) ១. ២. អត្រាតភ្ជាប់ដោយគុណភាព (ធន់-ជាសុកភាព) ១. ៣. ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព (អត្រាប្រើ/ចំណាយ) ២. ១. អត្រាជនបទមានទឹកកសិកម្មសមស្រប ២. ២. អត្រាអ្នកប្រើប្រាស់ប្រព័ន្ធស្រោចស្រពខ្នាតតូច ៣. ១. អត្រាជនបទមានហ៊ាមពលកកើតឡើងវិញ ៣. ២. អត្រាអ្នកប្រើប្រាស់ហ៊ាមពលកកើតឡើងវិញ ៤. ១. គោលនយោបាយ, យុទ្ធសាស្ត្រ, សកម្មភាព, វិភាជន៍ថវិកា, និងដឹកនាំសមស្រប ៤. ២. មានគោលការណ៍, នីតិវិធី, និងគ្រប់គ្រងធនធាន និងអនុវត្តថវិកាសមស្រប ៤. ៣. មានការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃសមស្រប ៥.១.ចូលរួមថែទាំផ្លូវជនបទជាប្រចាំ ៥.២.ទប់ស្កាត់បទល្មើសដឹកលើសទម្ងន់នាំឲ្យខូចផ្លូវ	? - ៥0%? ? - ៣0%? ? - ៧0%? យ៉ាងតិច ៥0% យ៉ាងតិច ៥0% យ៉ាងតិច ៣0% យ៉ាងតិច ៣0% - គោលនយោបាយផ្លូវ, ទឹកកសិកម្ម និងថាមពលកកើតឡើងវិញជនបទ - វិភាជន៍ និងអនុវត្តថវិកាសមស្រប - តាមដានត្រួតពិនិត្យនិងវាយតម្លៃសមស្រប - គ្រប់ផ្លូវជនបទត្រូវបានថែទាំជាប្រចាំ ដើម្បីធានា និរន្តភាពដល់ការដឹកជញ្ជូនគ្រប់ពេលវេលា

កម្មវិធីទី ៥ ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច		
គោលបំណងអនុកម្មវិធី	**សូចនាករគោល**	**គោលដៅ**
សាងមូលដ្ឋានគ្រឹះអភិបាលកិច្ចល្អ ១. ពង្រឹងការកសាងគោលនយោបាយ និងថវិកានីយកម្ម ២. ពង្រឹងការគ្រប់គ្រងធនធាន និងការអនុវត្តថវិកា ៣. ពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម ៤. ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ៥. ការគាំទ្រគោលនយោបាយនិងអភិបាលកិច្ចមូលដ្ឋានដោយមន្ទីរអភិវឌ្ឍន៍ជនបទ	១. ១. គោលនយោបាយរយៈពេលវែង និងមធ្យមសមស្រប ១. ២. មានកម្មវិធី និងយុទ្ធសាស្ត្រអនុវត្តសមស្រប ១. ៣. មានការរៀបចំ និងវិភាជថវិកាសមស្រប ២. ១. មានគោលការណ៍ និងនិតិវិធីសមស្រប ២. ២. មានប្រព័ន្ធគណនេយ្យ និងសន្ធិធិសមស្រប ២. ៣. មានការគ្រប់គ្រងធនធាន និងអនុវត្តថវិកាសមស្រប ៣. ១. មានប្រព័ន្ធ, គោលការណ៍, និងនីតិវិធីសមស្រប ៣. ២. មានយន្តការតាមដានត្រួតពិនិត្យវាយតម្លៃសមស្រប ៣. ៣. មានផែនការ និងការអនុវត្តផែនការសមស្រប ៤. ១. មានគោលនយោបាយ និងយុទ្ធសាស្ត្រសមស្រប ៤. ២. មានផែនការ និងការអនុវត្តផែនការ សមស្រប ៤. ៣. មានគោលការណ៍, នីតិវិធី, និងយន្តការវាយតម្លៃតម្រូវការ និងលទ្ធផលសមស្រប ៥.១. ចូលរួមរៀបចំ អនុវត្ត គ្រប់គ្រង ប្រើប្រាស់ថវិកាដោយតម្លាភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព	- គោលនយោបាយ ១០ឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកាសមស្រប - កម្មវិធី និងយុទ្ធសាស្ត្រអនុវត្តគោលនយោបាយសមស្រប - ការរៀបចំ និងវិភាជន៍ថវិកាប្រចាំឆ្នាំ សមស្រប - កំណត់គោលការណ៍ និងនីតិវិធីក្នុងការគ្រប់គ្រងធនធាន និងអនុវត្តថវិកាសមស្រប - កំណត់ប្រព័ន្ធគណនេយ្យ/សន្ធិធិ សមស្រប - គ្រប់គ្រងធនធាន/អនុវត្តថវិកាសមស្រប - កំណត់គោលការណ៍ និងនីតិវិធីតាមដានត្រួតពិនិត្យ និងវាយតម្លៃសមស្រប - កំណត់យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមស្រប - កសាងផែនការ និងអនុវត្តផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមស្រប - កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រកសាងធនធានមនុស្ស និងសមត្ថភាពស្ថាប័នសមស្រប - រៀបចំផែនការ និងអនុវត្តផែនការកសាងធនធានមនុស្ស និងសមត្ថភាពស្ថាប័នសមស្រប - កំណត់គោលការណ៍, នីតិវិធី, និងយន្តការវាយតម្លៃតម្រូវការ និងលទ្ធផលសមស្រប

V. តម្រូវការធនធានសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ថវិកា ឆ្នាំ២០២២-២០២៤

ដើម្បីសម្រេចចក្ខុវិស័យ និងគោលនយោបាយខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់កម្មវិធីចំនួន ៥ អមដោយអនុកម្មវិធីចំនួន ២២ ចង្កោមសកម្មភាព ១៤៩ និងសកម្មភាពមួយចំនួនតាមការចាំបាច់។ ក្នុងរយៈពេល ៣ ឆ្នាំ ២០២២-២០២៤ ក្រសួងអភិវឌ្ឍន៍ជនបទត្រូវការថវិកាចំនួន ២ ៩៥១ ៧៨១,៣ លានរៀល ក្នុងនោះសម្រាប់ឆ្នាំ២០២២ ចំនួន ៥៣៨ ៩៨២,៣ លានរៀល, ឆ្នាំ២០២៣ ចំនួន ៨៧៨ ៥១៣, ៦ លានរៀល, ឆ្នាំ២០២៤ ចំនួន ១ ៥៣៤ ២៨៥,៤ លានរៀល, បើធៀបនឹងផែន ការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ដែលមានចំនួន ៩៣៦ ១២៧ លានរៀល កញ្ចប់ថវិកា ៣ឆ្នាំរំកិលនេះមានកំណើន ៣១៥% ក្នុងនោះឆ្នាំ២០២២ មានកំណើន ១៧៤% ពីចំនួន ៣១០ ១៣០ លានរៀល, ឆ្នាំ២០២៣ មានកំណើន ២៧៤% ពីចំនួន ៣២០ ៣២៩ លានរៀល, ឆ្នាំ២០២៤ មានកំណើន ៤៧៩% ពីចំនួន ៣២០ ៣២៩លានរៀល។

ថវិកាសរុបរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងថវិកាដៃគូ សម្រាប់ឆ្នាំ២០២២-២០២៤ មានចំនួន ៣ ៣៦២ ០៨៧,៤ លានរៀល ក្នុងនោះថវិកាដៃគូចំនួន ៤១០ ៣០៦,១ លានរៀល។ សម្រាប់ថវិការដ្ឋ ដែលមានចំនួន ២ ៩៥១ ៧៨១,៣ លានរៀល មានចំណាយចរន្ត ១ ៦៤៣ ៣៨១,៣ លានរៀល និងចំណាយវិនិយោគថវិការដ្ឋចំនួន ១ ៣០៨ ៤០០,០ លានរៀល។ ក្នុងថវិកាចំណាយចរន្ត ១ ៦៤៣ ៣៨១,៣ លានរៀល មានចំណាយលើបន្ទុកបុគ្គលិកចំនួន ១០៣ ៥៤២,៨ លានរៀល និងក្រៅបន្ទុកបុគ្គលិកចំនួន ១ ៥៣៩ ៨៣៨,៥ លានរៀល។

គោលនយោបាយទី១៖ ការលើកកម្ពស់សុខុមាលភាពសង្គមជនបទ សម្រាប់រយៈពេល ៣ឆ្នាំត្រូវការថវិកាចំនួន ១៨៤ ១៤៧,០ លានរៀល ក្នុងនោះថវិការដ្ឋចំនួន ៩៧ ៤៣០,៧ លានរៀល និងថវិកាដៃគូចំនួន ៥៥ ០១១,១ លានរៀល។ ឆ្នាំ២០២២ ថវិការដ្ឋចំនួន ៣៦ ៩៩៧,៧ លានរៀល និងថវិកាដៃគូចំនួន ១៥ ៨៧៣,០ លានរៀល, ឆ្នាំ២០២៣ ថវិការដ្ឋចំនួន ៤៣ ១៤៦,៩ លានរៀល និងថវិកាដៃគូចំនួន ២១ ៨៥៣,០ លានរៀល, ឆ្នាំ២០២៤ ថវិការដ្ឋចំនួន ៤៨ ៩៩០,៣ លានរៀល និងថវិកាដៃគូចំនួន ១៧ ២៨៥,១ លានរៀល។

គោលនយោបាយទី២៖ ការបង្កើនសុខវឌ្ឍនភាពជនបទ សម្រាប់រយៈពេល ៣ឆ្នាំត្រូវការថវិកាចំនួន ៣ ១៧៧ ៩៤០,៤ លានរៀល ក្នុងនោះថវិការដ្ឋចំនួន ២ ៨២២ ៦៤៥,៤ លានរៀល និងថវិកាដៃគូចំនួន ៣៥៥ ២៩៥,០ លានរៀល។ ឆ្នាំ២០២២ ថវិការដ្ឋចំនួន ៥០១ ៩៨៣,៦ លានរៀល និងថវិកាដៃគូចំនួន ៨៨ ៣៩៤,៨ លានរៀល, ឆ្នាំ២០២៣ ថវិការដ្ឋចំនួន ៨៣៥ ៣៦៦,៧ លានរៀល និងថវិកាដៃគូចំនួន ១២៩ ៥៨៧,១ លានរៀល, ឆ្នាំ២០២៤ ថវិការដ្ឋចំនួន ១ ៤៨៥ ២៩៥, ១ លានរៀល និងថវិកាដៃគូចំនួន ១៣៣ ៣១៣,១ លានរៀល។

កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ត្រូវការថវិកាសរុបរយៈពេល ៣ឆ្នាំចំនួន ១១ ៥០៤,៩ លានរៀល ក្នុងនោះថវិការដ្ឋចំនួន ៩ ១៣៦,៨ លានរៀល និងថវិកាដៃគូចំនួន ២ ៣៦៨,១ លានរៀល ដោយរួមបញ្ចូលចំណាយបន្ទុកបុគ្គលិកចំនួន ២ ៥៣៤,១ លានរៀល និងក្រៅបន្ទុកបុគ្គលិកចំនួន ៦ ៦០២,៧ លានរៀល សម្រាប់រៀបចំបង្កើនប្រាក់ចំណូល បង្កើនជីវភាពរស់នៅរបស់ប្រជាជនជនបទឲ្យបានល្អប្រសើរ តាមរយៈបង្កើនផលិតភាពកសិកម្មជនបទ និងពិធីធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ការអភិវឌ្ឍទីផ្សារជនបទ រៀបចំគោលនយោបាយនិងអភិបាលកិច្ចសេដ្ឋកិច្ចជនបទដែលនឹងទទួលបានប្រាក់ ចំណូលមានការកើន ឡើងពី ១៣៥៥ ដុល្លា/នាក់/ឆ្នាំក្នុងឆ្នាំ២០១៩ ដល់ ១៧៦១,៥០ ដុល្លា/នាក់/ឆ្នាំ នៅឆ្នាំ២០២៣ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅតាមជនបទនៃប្រទេសកម្ពុជា។

កម្មវិធីអភិវឌ្ឍន៍សុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ ត្រូវការថវិកាសរុបរយៈពេល ៣ឆ្នាំចំនួន ១៣៥ ៧៧៧,៣ លានរៀល ក្នុងនោះថវិការដ្ឋចំនួន ៨៤ ៣៣៤,៣ លានរៀល និងថវិកាដៃគូចូលរួមមានចំនួន ៥១ ៤៤៣,០ លានរៀល ហើយក្នុងថវិកាចរន្តមានបន្ទុកបុគ្គលិកសរុបចំនួន ៧ ៨៩៦,៤ លានរៀល និងក្រៅបន្ទុកបុគ្គលិកមានចំនួន ៧៦ ៤៣៧,៩ លានរៀល។ កម្មវិធីនេះ មានគោលដៅបង្កើនសុខុមាលភាពសុខភាពជូនប្រជាជនជនបទ ដើម្បីទទួលបានសុខភាពមាំមួននៅក្នុងសង្គមជនបទ កាត់បន្ថយជំងឺរ៉ាំរ៉ៃ ជំងឺបន្ទាប់បន្សំផ្សេងៗ ក្នុងនោះក្រសួងនឹងផ្តល់ជូនសេវាទឹកស្អាតប្រកប ដោយសុវត្ថិភាពសម្រាប់ប្រើប្រាស់និងបរិភោគប្រចាំថ្ងៃ លុបបំបាត់ការបន្ទោរបង់ពាសវាលពាសកាល បង្កើនបរិស្ថានស្អាតជុំវិញលំនៅឋានក្នុងភូមិរហូតដល់ក្នុងសហគមន៍ទាំងមូល និងអភិវឌ្ឍន៍ធនធានមនុស្សជនបទដែលជាគោលដៅអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានមនុស្សនៅតាមតំបន់ជនបទដែលជាកម្លាំងស្នូលក្នុងការចូលរួមអភិវឌ្ឍន៍ជនបទ។

កម្មវិធីអភិវឌ្ឍន៍សហគមន៍ជនបទ ត្រូវការថវិកាសរុបរយៈពេល ៣ឆ្នាំចំនួន ៣៦ ៨៦៤,៨ លានរៀល ថវិការដ្ឋចំនួន ៣៥ ៦៦៤,៨ លានរៀល និងថវិកាដៃគូចូលរួមចំនួន ១ ២០០ លានរៀល និងត្រូវចំណាយលើបន្ទុកបុគ្គលិកចំនួន ៥ ៨៣៦,៩ លានរៀល និងក្រៅបន្ទុកបុគ្គលិក ចំនួន ២៨ ៩២៧,៩ លានរៀល។ កម្មវិធីនេះ មានគោលបំណងបង្កើនសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសហគមន៍ឲ្យបានល្អប្រសើរ និងបង្កើនសក្តិសិទ្ធភាពនិងប្រសិទ្ធភាពរចនាសម្ព័ន្ធសង្គមជនបទដើម្បី កសាងពលរដ្ឋល្អ និងសមូហភាពស្នូលនៅជនបទ។ កាត់បន្ថយអំពើចោរកម្ម ល្បែងស៊ីសង គ្រឿងញៀណ និងអំពើអសកម្មនានាក្នុងសហគមន៍ជនបទ។ គាំពារនិងអភិវឌ្ឍន៍សំណាញ់សុវត្ថិភាពក្នុងសហគមន៍ជនបទ ដើម្បីជួយគាំពារដល់ជនទីទ័លក្រ ជនងាយរងគ្រោះក្នុងសហគមន៍ពិសេសបង្កើតកម្មវិធីជួយសង្គ្រោះ គ្រួសារក្រីក្រ និងគ្រួសារដែលធ្លាក់ខ្លួនក្របណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ គ្រួសារដែលជំពាក់បំណុល ធនាគារន្តែការពុំអាចដោះស្រាយបាន តាមរយៈបង្កើតការងារ ផ្តល់ជំនាញ ផ្តល់ទុន ដើម្បីកែប្រែជីវភាព រស់នៅរបស់គ្រួសារទាំងនោះឲ្យមានលទ្ធភាពអាចរស់នៅសមរម្យក្នុងសហគមន៍ជនបទដូចគ្រួសារដទៃទៀតដែរ។ អភិវឌ្ឍន៍គុណតម្លៃសហគមន៍ដើម្បីឲ្យសហគមន៍ត្រូវបានទទួលស្គាល់ និងចូលរួមអភិវឌ្ឍន៍ ទាំងអស់គ្នាក្នុងស្មារតីទទួលខុសត្រូវរួមមានសាមគ្គីភាព និងចូលរួមដោះស្រាយបញ្ហាក្នុងសហគមន៍ ចែករំលែកព័ត៌មានគ្នាទៅវិញទៅមក

ដើម្បីទទួលបានផលប្រយោជន៍រួមក្នុងសហគមន៍។ អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ដើម្បីឲ្យជនជាតិដើមក្នុងប្រទេសកម្ពុជាទទួលបានការអភិវឌ្ឍ និងមានសិទ្ធិដូចពលរដ្ឋភាគច្រើននឹងគេ ក្រៅពីនេះ ជនជាតិដើមភាគតិចក៏នឹងត្រូវបាន អភិរក្ស វប្បធម៌ ប្រពៃណី របស់ពួកគាត់ផងដែរ។

កម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទ ត្រូវការថវិកាសម្រាប់រយៈពេល ៣ឆ្នាំសរុបចំនួន ២ ៩៦៨ ៦៨៨,៧ លានរៀល ដែលក្នុងនោះថវិការដ្ឋ ២ ៦២៥ ៣៩៣,៧ លានរៀល និងគម្រោងដៃគូចូលរួមមានថវិកាសរុបចំនួន ៣៤៣ ២៩៥ លានរៀល ដោយរួមបញ្ចូលបន្ទុកបុគ្គលិកចំនួន ៥ ៤៤៤,៤ លានរៀល និងចំណាយក្រៅបន្ទុកបុគ្គលិកចំនួន ១ ៣១២ ៤៤៩,៣ លានរៀល សម្រាប់ប្រែក្លាយតំបន់ជនបទឲ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមាហរណ ដើម្បីតភ្ជាប់តំបន់ជនបទទាំងមូល ក្នុងនោះ មាន តភ្ជាប់ផ្លូវក្នុងភូមិទៅកាន់ឃុំ ស្រុក និងខេត្ត ដើម្បីបង្កើនទំនាក់ទំនងក្នុងសហគមន៍ជនបទ ជាបណ្តាញ ដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងសហគមន៍ផ្ទាល់ និងពីខាងក្រៅសហគមន៍ងាយស្រួល មកកាន់ទីផ្សារ សាលារៀន មណ្ឌលសុខភាព មជ្ឈមណ្ឌលពាណិជ្ជកម្ម និងកន្លែងដទៃទៀត ដែលអាច ឲ្យប្រជាជនធ្វើដំណើរបានគ្រប់ពេលវេលា គ្រប់ទីកន្លែងនិងគ្រប់រដូវកាល។ កម្មវិធីនេះ ក៏បានគិតគូរ ពីការសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូចៗនៅក្នុងសហគមន៍ ដើម្បីធានាការផ្គត់ផ្គង់ទឹកសម្រាប់ធ្វើស្រែ ចំការតាមបែបទំនើប ធានាឲ្យមានប្រព័ន្ធទឹកដែលមានលទ្ធភាពអាចស្រោចស្រពលើផ្ទៃដីចំការស្រែរបស់ប្រជាជនក្នុងសហគមន៍ដើម្បីបង្កើនទិន្នផល គាំទ្រដល់លទ្ធភាពបង្កើនប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជាកសិករនៅជនបទ។ ដើម្បីគាំទ្រដល់ការបង្កើនផលិតផលកសិកម្មក្រសួងក៏មានកម្មវិធីអភិវឌ្ឍន៍ថាមពល កកើតឡើងវិញនៅតំបន់ជនបទ សម្រាប់តំបន់ជនបទដាច់ស្រយាលដែលគ្មានចរន្ត អគ្គិសនីទៅដល់។ ការទាញយកថាមពលព្រះអាទិត្យ មកប្រើសម្រាប់បម្រើការងារកសិកម្ម ទាញយកទឹកមកស្រោចស្រពលើដីដំណាំកសិកម្ម និងបង្កើនជីវភាពរស់នៅក្នុងតំបន់ជនបទ។ កម្មវិធីនេះ ក៏នឹងមានការអភិវឌ្ឍគោលនយោបាយ និងអភិបាលកិច្ចហេដ្ឋារចនាសម្ព័ន្ធជនបទផងដែរ ដើម្បីធានាពីប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ។

កម្មវិធីអភិវឌ្ឍន៍គោលនយោបាយនិងពង្រឹងអភិបាលកិច្ច ត្រូវការថវិកាសម្រាប់រយៈពេល ៣ឆ្នាំ សរុបចំនួន ២០៩ ២៥១,៧ លានរៀល ដែលក្នុងនោះថវិការដ្ឋ ១៩៧ ២៥១,៧ លានរៀល និងគម្រោងដៃគូចូលរួមមានថវិកាសរុបចំនួន ១២ ០០០ លានរៀល ដោយរួមបញ្ចូលបន្ទុកបុគ្គលិកចំនួន ៨១ ៨៣១,០ លានរៀល និងបន្ទុកក្រៅបុគ្គលិកចំនួន ១១៥ ៤២០,៧ លានរៀល។ កម្មវិធីនេះ មានគោលដៅពង្រឹងប្រសិទ្ធភាព សក្តិសិទ្ធិភាព តម្លាភាពក្នុងការគ្រប់គ្រងថវិកា ការវិភាជន៍ថវិកា ការប្រើប្រាស់ថវិកាដើម្បីបង្កើនអភិបាលកិច្ចល្អ ពិសេសការពង្រឹងស្ថាប័ន។ កម្មវិធីនេះ នឹងជួយសម្របសម្រួលគ្រប់កម្មវិធី ទាំងបួនខាងលើក្នុងការរៀបចំគោលនយោបាយតាមផ្នែក ពង្រឹងការគ្រប់គ្រងធនធានមនុស្សសម្រាប់ កិច្ចដំណើរការក្រសួងទាំងមូល។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មថវិកាកម្មវិធី និងដៃគូ ការធ្វើសវនកម្មផ្ទៃក្នុងការធ្វើអធិការកិច្ចនឹងត្រូវបានពង្រឹងសម្រាប់ចូលរួមអនុវត្តកម្មវិធីទាំង៥។ អនុលោមតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការវិសហមជ្ឈការ កំណែ

ទម្រង់រដ្ឋបាល ដើម្បីធានាការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលសម្រេចតាមគោលដៅ ដែលបានគ្រោងទុក។ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ក្រសួងគ្រោងនឹងបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍និងស្រាវជ្រាវការអភិវឌ្ឍជនបទនៅតាមតំបន់ទាំង ៥ ផងដែរ។ តម្រូវការថវិកាតាមកម្មវិធី, អនុកម្មវិធី, និងតាមឆ្នាំនីមួយៗមានបង្ហាញលម្អិតក្នុងឧបសម្ព័ន្ធ៣។

តារាងទី៤ៈ តម្រូវការថវិកាតាមអនុកម្មវិធីសម្រាប់រយៈពេលមធ្យម

ឈ្មោះកម្មវិធី/អនុកម្មវិធី	ឆ្នាំ២០២២- ២០២៤		
	សរុបរួម	ថវិការដ្ឋ	ថវិកាដៃគូ
កម្មវិធីទី ១. អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ	**11,504.9**	**9,139.8**	**2,368.1**
១.១.ការអភិវឌ្ឍកសិកម្មជនបទ ផ្តោតលើក្សេត្រជីវកម្ម	231.4	115.4	116.0
១.២.ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ	903.3	795.9	107.4
១.៣.ការអភិវឌ្ឍន៍ទីផ្សារជនបទ	4,362.2	2,579.0	1,783.2
១.៤.ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច	2,982.0	2,620.5	361.5
- អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយមន្ទីរាជធានីខេត្ត	3,026.0	3,026.0	0.0
កម្មវិធីទី ២. អភិវឌ្ឍន៍សុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ	**135,777.3**	**84,334.3**	**51,443.0**
២.១.ការអភិវឌ្ឍទឹកស្អាតជនបទ	77,255.5	29,127.5	48,128.0
២.២.ការអភិវឌ្ឍអនាម័យជនបទ	41,443.5	38,128.5	3,315.0
២.៣.ការលើកកម្ពស់បរិស្ថានជនបទ	590.0	590.9	0.0
២.៤.ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច	0.0	0.0	0.0
-អភិវឌ្ឍន៍សុខភាព និងកែលម្អ លក្ខខណ្ឌរស់នៅជនបទ ដោយមន្ទីរ រាជធានីខេត្ត	16,487.4	16,487.4	0.0
កម្មវិធីទី ៣. អភិវឌ្ឍន៍សហគមន៍ជនបទ	**36,864.8**	**35,664.8**	**1,200.0**
៣.១.ការរក្សាសន្តិសុខ និងសុវត្ថិភាពសហគមន៍ជនបទ	3,348.0	3,348.0	0.0
៣.២.អភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសហគមន៍ជនបទ	1,600.0	1,600.0	0.0
៣.៣.ការអភិវឌ្ឍគុណតម្លៃសហគមន៍ជនបទ	14,990.0	14,990.0	0.0
៣.៤.អភិរក្ស និងអភិវឌ្ឍន៍នជាតិដើមកាគតិច	3,412.9	3,412.9	0.0
៣.៥.ការអភិវឌ្ឍធនធានមនុស្សជនបទ	5,100.0	3,900.0	1,200.0
៣.៦.ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច	120.0	120.0	0.0
- អភិវឌ្ឍន៍សហគមន៍ជនបទ ដោយមន្ទីរាជធានីខេត្ត	8,293.9	8,293.9	0.0
កម្មវិធីទី ៤. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ	**2,968,688.7**	**2,625,393.7**	**343,295.0**

ឈ្មោះកម្មវិធី/អនុកម្មវិធី	ឆ្នាំ២០២២- ២០២៤		
	សរុបរួម	ថវិការដ្ឋ	ថវិការៃគ
កម្មវិធីទី ៤. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត និងគមនាគមន៍ជនបទ	**2,968,688.7**	**2,625,393.7**	**343,295.0**
៤.១.ការអភិវឌ្ឍផ្លូវជនបទ និងសំណង់សិល្បការ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ	2,679,119.4	2,422,944.4	256,175.0
៤.២.ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពកសិកម្មខ្នាតតូចជនបទ	178,120.0	91,000.0	87,120.0
៤.៣.ការអភិវឌ្ឍថាមពលកកើតឡើងវិញនៅតំបន់ជនបទ	12,000.0	12,000.0	0.0
៤.៤.ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច	2,700.0	2,700.0	0.0
-អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ ដោយ មន្ទីររាជធានីខេត្ត	96,749.3	96,749.3	0.0
កម្មវិធីទី ៥. អភិវឌ្ឍន៍គោលនយោបាយ និងពង្រឹងអភិបាលកិច្ច	**209,251.7**	**197,251.7**	**12,000.0**
៥.១.ពង្រឹងការកសាងគោលនយោបាយ និងថវិកានីយកម្ម	4,700.0	4,700.0	0.0
៥.២.ពង្រឹងការគ្រប់គ្រងធនធាន និងការអនុវត្តថវិកា	87,089.6	87,089.6	0.0
៥.៣.ពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម	4,671.4	4,671.4	0.0
៥.៤.ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន	22,937.3	10,937.3	12,000.0
-អភិវឌ្ឍន៍គោលនយោបាយ និងពង្រឹងអភិបាលកិច្ច ដោយមន្ទីរ រាជធានីខេត្ត	89,853.4	89,853.4	0.0
សរុបរួម	3,362,087.4	2,951,781.3	410,306.1

VI. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ គឺជាផែនការយុទ្ធសាស្ត្រដ៏មានសារសំខាន់និងចាំបាច់បំផុតសម្រាប់ចាប់ផ្តើម **កសាងមូលដ្ឋានគ្រឹះនៃសង្គមជនបទស៊ីវិល័យនៃចក្ខុវិស័យកសាងសង្គមជនបទស៊ីវិល័យនៅ ឆ្នាំ២០៣០** ដែលជាគោលបំណងនៃគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២១-២០៣០ ក្នុងការរួមចំណែកលុបបំបាត់ភាពក្រីក្រនិងកសាងប្រទេសកម្ពុជាឲ្យមានចំណូលមធ្យមកម្រិតខ្ពស់នៅ ឆ្នាំ២០៣០ ដែលជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញនូវគោលនយោបាយ **"លើកកម្ពស់សុខមាលភាពនិងបង្កើនសុខវឌ្ឍនភាពសង្គមជនបទ"** ដែលត្រូវគាំទ្រដោយកម្មវិធី ៥គឺអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ, អភិវឌ្ឍន៍សុខភាពនិងកែម្អលគុណភាពជីវិតនៅជនបទ, អភិវឌ្ឍន៍សហគមន៍ជនបទ, អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទ, និងអភិវឌ្ឍន៍គោលនយោបាយនិងពង្រឹងអភិបាលកិច្ច ក្នុងគោលដៅធានាឲ្យតំបន់ជនបទមានជីវភាពសមរម្យ, មានសុខភាពមាំមួន, មានសហគមន៍ថ្លៃថ្នូរ, មានលក្ខណសមាហរណ, និងមានគោលនយោបាយនិងអភិបាលកិច្ចល្អ។

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២២-២០២៤ ដែលជាជំណាក់កាលទី១ ក្នុងការកសាងមូលដ្ឋានគ្រឹះនៃសង្គមជនបទស៊ីវិល័យ ដែលមានគោលដៅកសាងមូលដ្ឋានគ្រឹះជីវភាពសមរម្យ, មូលដ្ឋានគ្រឹះសុខភាពមាំមួន, មូលដ្ឋានគ្រឹះសហគមន៍ថ្លៃថ្នូរ, មូលដ្ឋានគ្រឹះជនបទសមាហរណ, និងមូលដ្ឋានគ្រឹះគោលនយោបាយនិងអភិបាលកិច្ចល្អ ក្រសួងអភិវឌ្ឍន៍ជនបទត្រូវការថវិកាសរុបរយៈពេល ៣ឆ្នាំ ប្រមាណ ៣, ៤ពាន់លានរៀល ឬ ប្រមាណ ១, ១ពាន់លានរៀលក្នុងមួយឆ្នាំ ដែលប្រមាណ ៨០% តាមរយៈថវិការដ្ឋ និង ២០% តាមរយៈថវិកាដៃគូអភិវឌ្ឍន៍។ បើធៀបនឹងថវិកា២០២១-២០២៣ ឬថវិកា២០២១ តម្រូវការចំណាយនេះមានកម្រិតខ្ពស់មែន ប៉ុន្តែបើធៀបនឹងគោលនយោបាយ, កម្មវិធី, យុទ្ធសាស្ត្រ, និងគោលដៅដែលបានដាក់ចេញនិងត្រូវសម្រេចឲ្យបានគឺពិតជាជាក់ស្តែងនិងសមស្រប។

ផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤ គឺជាជំហានថ្មីមួយទៀតក្នុងការរួមចំណែកជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណ ដើម្បីធានាបង្កើនស័ក្តិសិទ្ធិភាព, ប្រសិទ្ធភាព, ផលិតភាព, គណនេយ្យភាព, និងតម្លាភាព ក្នុងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្ពោះទៅសម្រេចឲ្យបាននូវសុខុមាលភាពនិងសុខវឌ្ឍនភាពសង្គមជនបទ ដែលជាគោលដៅនៃការកសាងសង្គមជនបទស៊ីវិល័យនៃគោលបំណងគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ក្នុងការរួមចំណែកលុបបំបាត់ភាពក្រីក្រ និងកសាងប្រទេសកម្ពុជាឲ្យមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

រដ្ឋមន្ត្រី

បណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន

តារាងឧបសម្ព័ន្ធ

តារាងឧបសម្ព័ន្ធ១៖ រចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ត្រូវបានបែងចែកការគ្រប់គ្រង និងអត្តភាពទទួលខុសត្រូវ

ឈ្មោះ គោលបំណង គោលនយោបាយ	ឈ្មោះ កម្មវិធី និង អនុកម្មវិធី	អ្នកគ្រប់គ្រង	អត្តភាពទទួលខុសត្រូវ
	កម្មវិធីទី១ ៖ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ	**អគ្គនាយករងបច្ចេកទេស**	**អគ្គនាយកដ្ឋានបច្ចេកទេស**
	អនុកម្មវិធីទី១.១ ៖ ការអភិវឌ្ឍកសិកម្មជនបទ	ប្រធាននាយកដ្ឋាន	ន.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
	អនុកម្មវិធីទី១.២ ៖ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ	ប្រធាននាយកដ្ឋាន	ន.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
	អនុកម្មវិធីទី១.៣ ៖ ការអភិវឌ្ឍទីផ្សារជនបទ	ប្រធាននាយកដ្ឋាន	ន.អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
គោលនយោបាយ ទី១. លើកកម្ពស់ សុខុមាលភាព សង្គមជនបទ	អនុកម្មវិធីទី១.៤ ៖ ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងអភិបាលកិច្ច សេដ្ឋកិច្ចជនបទ	ប្រធាននាយកដ្ឋាន	អគ្គនាយកដ្ឋានបច្ចេកទេស
	អនុកម្មវិធីទី១.៥ ៖ ការលើកកម្រិតជីវភាពរស់នៅតាមគ្រួសារនៅជនបទ ដោយមន្ទីរាជធានីខេត្ត	ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ	មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត២៥
	កម្មវិធីទី២ ៖ ការអភិវឌ្ឍសុខភាព និងកែលម្អលក្ខខណ្ឌរស់នៅជនបទ	**អគ្គនាយករងបច្ចេកទេស**	**អគ្គនាយកដ្ឋានបច្ចេកទេស**
	អនុកម្មវិធីទី២.១ ៖ ការអភិវឌ្ឍទឹកស្អាតជនបទ	ប្រធាននាយកដ្ឋាន	ន.ផ្គត់ផ្គង់ទឹកជនបទ
	អនុកម្មវិធីទី២.២ ៖ ការអភិវឌ្ឍអនាម័យជនបទ	ប្រធាននាយកដ្ឋាន	ន.សុខភាពជនបទ
	អនុកម្មវិធីទី២.៣ ៖ ការអភិវឌ្ឍបរិស្ថានជនបទ	ប្រធាននាយកដ្ឋាន	ន.សុខភាពជនបទ

ឈ្មោះ គោលបំណង គោលនយោបាយ	ឈ្មោះ កម្មវិធី និង អនុកម្មវិធី	អ្នកគ្រប់គ្រង	អ្នកភាពទទួលខុសត្រូវ
	អនុកម្មវិធីទី២.៤ ៖ ការអភិវឌ្ឍគោលនយោបាយ និងអភិបាលកិច្ច សុខភាពជនបទ	ប្រធាននាយកដ្ឋាន	អគ្គនាយកដ្ឋានបច្ចេកទេស
	អនុកម្មវិធីទី២.៥ ៖ ការផ្តល់សេវាសុខភាព និងលក្ខខណ្ឌនៃការរស់នៅជនបទដោយមន្ទីរាជធានីខេត្ត	ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ	មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត២៥
	កម្មវិធីទី៣ ៖ ការអភិវឌ្ឍសហគមន៍ជនបទ	**អគ្គនាយករងបច្ចេកទេស**	**អគ្គនាយកដ្ឋានបច្ចេកទេស**
	អនុកម្មវិធីទី៣.១ ៖ការរក្សាសន្តិសុខ និងសុវត្ថិភាពសហគមន៍ជនបទ	ប្រធាននាយកដ្ឋាន	ន. អភិវឌ្ឍន៍សហគមន៍
	អនុកម្មវិធីទី៣.២ ៖ការគាំពារ និងអភិវឌ្ឍន៍សំណាញ់សុវត្ថិភាពសហគមន៍	ប្រធាននាយកដ្ឋាន	ន. អភិវឌ្ឍន៍សហគមន៍
	អនុកម្មវិធីទី៣.៣ ៖ការអភិវឌ្ឍគុណតម្លៃសហគមន៍ជនបទ	ប្រធាននាយកដ្ឋាន	ន. អភិវឌ្ឍន៍សហគមន៍
	អនុកម្មវិធីទី៣.៤ ៖អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច	ប្រធាននាយកដ្ឋាន	ន.អភិវឌ្ឍន៍ជនជាតិដើមភាគតិច
